

# ភាពថ្លៃថ្នូរ ទទួលបានវិញ



# Dignity regained

ក្រសួងសុខាភិបាល

មជ្ឈមណ្ឌលជាតិ
កំចាត់រោគរបេងនិងរោគឃ្លង់

The Nippon Foundation
SASAKAWA MEMORIAL
HEALTH FOUNDATION

## មាតិកា *(ភាពថ្លៃថ្នូរទទួលបានវិញ)*


| | | ទំព័រ |
|---|---|---|
| ១ | ដំណើររឿងទី ១ | ៥ |
| ២ | ដំណើររឿងទី ២ | ១០ |
| ៣ | ដំណើររឿងទី ៣ | ១៥ |
| ៤ | ដំណើររឿងទី ៤ | ២១ |
| ៥ | ដំណើររឿងទី ៥ | ២៥ |
| ៦ | ដំណើររឿងទី ៦ | ៣០ |
| ៧ | ដំណើររឿងទី ៧ | ៣៥ |
| ៨ | ដំណើររឿងទី ៨ | ៤០ |
| ៩ | ដំណើររឿងទី ៩ | ៤៤ |
| ១០ | ដំណើររឿងទី ១០ | ៤៩ |


## Table of contents *(Dignity Regained)*


| | | Page |
|---|---|---|
| 1. | Story_1 | 5 |
| 2. | Story_2 | 10 |
| 3. | Story_3 | 15 |
| 4. | Story_4 | 21 |
| 5. | Story_5 | 25 |
| 6. | Story_6 | 30 |
| 7. | Story_7 | 35 |
| 8. | Story_8 | 40 |
| 9. | Story_9 | 44 |
| 10. | Story_10 | 49 |

# អារម្ភកថា

នៅប្រទេសកម្ពុជា ជំងឺឃ្លង់គឺជាជំងឺមួយដែលកើតជាយូរលង់ណាស់មកហើយ គឺមិនចំពោះអ្នកក្រ អ្នកមាន សេដ្ឋី មន្ត្រី ឬរាស្ត្រនោះឡើយ ។ ជំងឺនេះគេតែង យល់ច្រឡំថា ជាជំងឺសូរពូជ ជំងឺឆ្លងមកពីរោគស្វាយ អំពើអំពាន់ អាបធ្មប់ បិសាច ឬជាការដាក់បណ្តាសារបស់ព្រះអាទិទេព។

សម័យមុន ប្រជារាស្ត្រខ្មែរមានការតក់ស្លុត ភ័យខ្លាចយ៉ាងខ្លាំង ដែលគេចាត់ទុកថា ឃ្លង់គឺជារោគមួយកាចសាហាវបំផុតហើយគេមិនរាប់រកទៀតផង។ ម្ល៉ោះហើយអ្នកដែលកើតជំងឺឃ្លង់ត្រូវគេបណ្តេញចេញពីភូមិ ឃុំ ស្រុក ឱ្យទៅរស់នៅតំបន់ឆ្ងាយដាច់ស្រយាល ។ ជាឧទាហរណ៍ កាលពីមុនឆ្នាំ ១៩៧០ អ្នកដែលកើតជំងឺឃ្លង់ ត្រូវគេប្រមូលផ្តុំឱ្យទៅនៅតំបន់ពិសេសមួយកន្លែងគឺភូមិត្រើង ឃុំមៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម។

មកដល់សម័យប៉ុលពត ទើបពួកអ្នកកើតឃ្លង់ទាំងនោះ ភៀសខ្លួនរាយប៉ាយគ្រប់ខេត្ត-ក្រុងទាំងអស់។ លុះមកដល់ពាក់កណ្តាលទសវត្សរ៍៨០ ក្រសួងសុខាភិបាលក៏បានរៀបចំសេវាព្យាបាលជំងឺឃ្លង់ចាប់តាំងពីថ្នាក់ជាតិ និង ពង្រីកជាបន្តបន្ទាប់ទៅគ្រប់ខេត្ត ស្រុក និងមណ្ឌលសុខភាព។ ជាមួយគ្នានេះដែរនៅដើមទសវត្សរ៍៨០នេះ ពិភពលោកទាំងមូលបានដំណើរការព្យាបាលជំងឺឃ្លង់ដោយថ្នាំច្រើនមុខ (MDT) តាមការណែនាំរបស់អង្គការសុខភាពពិភពលោកធ្វើឱ្យជាសះស្បើយមួយរយភាគរយ ដែលធ្វើឱ្យសហគមន៍ អ្នកកើតជំងឺមានការជឿជាក់ និងចូលមកព្យាបាលជាបណ្តើរៗរហូតមក។

ជាបន្តមកទៀតដោយមានការចូលរួមសហការពីដៃគូអង្គការនានា មានជាអាទិ CIOMAL, SASAKAWA MEMORIAL HEALTH FOUNDATION, WHO, NLR, CHILD FUND... និងមានការគាំទ្រពីអាជ្ញាធរគ្រប់ជាន់ថ្នាក់ព្រមទាំងប្រជាពលរដ្ឋ កម្មវិធីជាតិកំចាត់រោគហង់សិនបានបើកយុទ្ធនាការជាបន្តបន្ទាប់ព្រមទាំងទទួលជោគជ័យ រហូតដល់បានសម្រេចគោលដៅ ក្នុងការកាត់បន្ថយជំងឺហង់សិនមិនឱ្យមានជាបញ្ហាក្នុងសុខភាពសាធារណៈ គឺអត្រាប្រេវ៉ាឡង់តិចជាង១ករណីជំងឺ ក្នុងចំណោមប្រជាពលរដ្ឋ ១០.០០០នាក់ តាំងពីឆ្នាំ១៩៩៨ ។

ទោះបីជាយើងបានកាត់បន្ថយមិនឱ្យមានជាបញ្ហា ក្នុងសុខភាពសាធារណៈក៏ដោយក៏កម្មវិធីជាតិបានខិតខំរិះរកយុទ្ធសាស្ត្រថ្មីៗជាបន្តបន្ទាប់ ដើម្បីឱ្យអត្រានេះកាន់តែចុះទាបទៅៗ រហូតដល់ឆ្នាំ២០០៨កន្លងមកនេះ យើងសម្រេចការកាត់បន្ថយថ្នាក់ ខេត្ត-ក្រុង ២៣ លើ ២៤ ។

សៀវភៅ*ភាពថ្លៃថ្នូរទទួលបានវិញ*នេះ ចងក្រងឡើងក្នុងគោលបំណងចូលរួមក្នុងការកាត់បន្ថយអត្រាប្រេវ៉ាឡង់ជំងឺឃ្លង់ឱ្យនៅទាបបំផុត និងលុបបំបាត់ភាពពិការឱ្យបានជាស្ថាពរក្នុងអនាគតដ៏ខ្លីខាងមុខនេះ រួមជាមួយចង់លុបបំបាត់អបិយជំនឿ និងការរើសអើងចំពោះអ្នករងគ្រោះដោយសារជំងឺឃ្លង់ទៀតផង ។

តាមទស្សនៈរបស់យើងខ្ញុំ ទោះបីប្រើគ្រប់យុទ្ធវិធីយ៉ាងណាក៏ដោយ ការលុបបំបាត់ជំងឺនេះឱ្យអស់ពីប្រទេសកម្ពុជាគឺជារឿងមិនងាយស្រួលនោះឡើយ ។ ដើម្បីចូលរួមបន្ថែមទៀត យើងខ្ញុំសម្រេចចិត្តលាតត្រដាងពីជីវិតពិតរបស់អ្នកពិការដោយសារជំងឺឃ្លង់ ព្រមទាំងទុក្ខលំបាករបស់ពួកគេ ។ ម្យ៉ាងវិញទៀតយើងមានបំណងឱ្យជនរួមជាតិ និងអន្តរជាតិបានយល់ច្បាស់ ដើម្បីជួយផ្តល់ជាយោបល់ និងស្វែងរកដំណោះស្រាយដ៏ល្អដើម្បីចូលរួមប្រយុទ្ធនឹងជំងឺឃ្លង់ឱ្យបានកាន់តែប្រសើរទៅថ្ងៃអនាគត ។

សៀវភៅនេះ វាមានអត្ថន័យវិសេសវិសាលណាស់ព្រោះជាកម្លាំងមួយសម្រាប់ពន្យល់បង្ហាញពីការប្រយុទ្ធនឹងជំងឺឃ្លង់ ព្រមទាំងគោលបំណងចង់លុបបំបាត់ស្លាកស្នាមដែលមានជាយូរលង់ណាស់មកហើយ ។

សៀវភៅនេះ ក៏បានអនុញ្ញាតឱ្យអ្នកពិការដោយសារជំងឺឃ្លង់មួយចំនួនបានលាតត្រដាងពីបទពិសោធ និងការតស៊ូរបស់ខ្លួនដើម្បីផ្សព្វផ្សាយឱ្យមនុស្សទូទៅបានយល់ច្បាស់ពីពួកគេ ។

ជាទីបញ្ចប់ យើងខ្ញុំសូមថ្លែងអំណរគុណដល់ អ្នករងគ្រោះដោយសារជំងឺឃ្លង់ដែលបានចូលរួមលាតត្រដាងពីជីវិតពិតទាំងនេះ ព្រមទាំងអង្គការនានាដែលបានចូលរួមការងារឃ្លង់ ព្រមទាំងថវិកាក្នុងការធ្វើឱ្យសៀវភៅនេះបានសម្រេចក្នុងការបោះពុម្ព ។

# PREFACE

In Cambodia, leprosy was affected not only poor people, also rich people, millionaire, official staff or general population. It was confused to hereditary disease, belonged to syphilis, witchcraft or sorcery or insult of the God.

In the past, Khmer people are afraid to this disease and set as serious disease and discriminate by the community. In the result, if anyone affected by leprosy, they should throw out of the community or village to live alone or in remote area. For example, before 1970, people affected by leprosy should collect to live in Treung village (Leprosarium), Mean Commune, Preychhor District, Kampong Cham Province.

In the Pol Pot Regime, they escape to live scattered in whole country. To the mid-decade 80, Ministry of Health organized Leprosy services from National level and expend step by step to all Province, District and Health center level.

As formula recommended by World Health organization, the leprosy patient was healed 100% that make their community believe this treatment and access to services until present. Later, with cooperation of partners such as **CIOMAL, SASAKAWA MEMORIAL HEALTH FOUNDATION, WHO, NLR, CHILD FUND...**, and support of all level of authorities and people, the National Leprosy Control Program have conducted many campaigns with successful and reached their elimination goal, prevalence less than 1 case among 10.000 people since 1998.

Even though we reduced the public health problem due to leprosy, the National Program has tried to find new strategies to reduce this prevalence, until 2008 we succeed the elimination in 23 provinces among 24.

This *dignity regained* stories' book is created to participate in the reduction of leprosy prevalence at minimum rate and to eliminate disability in the near future, with elimination of conviction and discrimination against people affected by leprosy.

With our opinion, whether we use such strategies, elimination convictions in Cambodia toward leprosy is not easy. To contribute these activities, we decide to extend true stories of disabled people affected by leprosy. In the other hand, for the National and International Community give recommendation toward good solutions in the participation of Leprosy control program in the best future.

This book has their particular definition because it is reinforced to explain in the fight of bad record presented long time ago. It also allows disabled people affected by leprosy to display their experience and their fight for knowing themselves toward general population.

Finally, I would like to thank to people affected by leprosy for their contribution of their own true stories and Organizations that support leprosy activities and funds to publish this book.

Lai Ky MD, Ph. D
Officer in charge
National Leprosy Elimination Programme



*ខ្ញុំមានជំនាញ ខ្ញុំមានមុខរបរ ខ្ញុំបានដំណើរការវាបានល្អ ហើយរស់នៅដូចអ្នកដទៃក្នុងភូមិ ។ ខ្ញុំរស់នៅដោយរីករាយជាមួយគ្រួសារខ្ញុំ ។ នៅពេលទំនេរ ខ្ញុំចូលរួមជាមួយក្រុមតន្ត្រីប្រចាំស្រុកក្នុងឋានៈជាអ្នកចម្រៀង ដោយសារខ្ញុំមានទឹកដមសម្លេងដូចអធិរាជសម្លេងមាស – លោក ស៊ីន ស៊ីសាមុត ។*

*ខ្ញុំសប្បាយរីករាយនឹងជម្រាបជូនពីប្រវត្តិពិតរបស់ខ្ញុំ ...*

***I have a skill and have my own job, and it runs smoothly. I live normaly as anyone else in the village and live happily with my family. When I have a free-time, I always participate in the local band as a singer because my voice is similar to a famous Cambodia singer, Mr. Sin Sisamuth.***

***I am really happy to tell you about my real story:***

នេះជាការបញ្ជាក់ ពីបុរសដែលបានរងគ្រោះដោយសារជំងឺឃ្លង់ម្នាក់នៅខេត្តព្រៃវែង។ គាត់មានជំនាញជាជាងអេឡិចត្រូនិក ជួសជុលវិទ្យុ ទូរទស្សន៍ ម៉ាញ៉េ...។ល។ នៅពេលទំនេរ គាត់ជួយគ្រួសារក្នុងកិច្ចការស្រែនិងចិញ្ចឹមជ្រូក។ គាត់រស់នៅយ៉ាងរីករាយក្នុងសង្គមដោយគ្មានការរើសអើង។សព្វថ្ងៃគាត់រស់នៅក្នុងស្រុកកញ្ជ្រៀច ខេត្តព្រៃវែង។ គាត់ជាកូនពៅក្នុងចំណោមបងប្អូនបួននាក់ គឺស្រីម្នាក់ និងប្រុសបីនាក់។ គាត់មិនដឹងថាវាជារឿងគ្រោះថ្នាក់ ឬក៏ជារឿងព្រហ្មលិខិតទេក៏មិនដឹង? ព្រោះម្តាយគាត់ និងបងទាំងបីពុំមានអ្នកណាកើតរោគដូចរូបគាត់ឡើយ។ ក្នុងឆ្នាំ២០០២ គាត់មានស្នាកស្នាមមួយនៅស្មាឆ្វេង តែគាត់ហាក់ដូចជាគ្មានការចាប់អារម្មណ៍សោះ ព្រោះឪពុកគាត់មានស្នាកស្នាមពេញតែខ្លួន។ មួយឆ្នាំកន្លងទៅ ក៏លេចចេញស្នាមសត្វចមួយ នៅខាងក្រោមភ្នែកឆ្វេង ហើយថ្លើមដៃគាត់ទាំងសងខាងក៏ចាប់ផ្តើមស្វិត។ ខណៈនោះគាត់ក៏ចាប់ផ្តើមសង្ស័យថាជារោគឆ្លងពីឪពុកគាត់ហើយ។

This is the affirmation made by a man affected by leprosy in Prey Veng province. He has a skill as an electronic technician. He repairs radio sets, televisions, VCD, DVD, electric fans and other appliances. When he has free time, he helps his family to work in the rice field and in the piggery to raise pigs. He lives happily in the society without discrimination. Nowadays, he is living in Kanh Chreach District, Prey Veng Province.

He is the last son among four siblings, one girl and three boys. He didn't know if it was an accident or it is a punishment for his sins because his mother and the other three of his siblings didn't have this disease. In 2002, a spot appeared on the skin of his left shoulder but he didn't notice it because his father had spots all over his body. One year later, another spot appeared under his left eye, and soon after, his finger muscles became weak. At that time, he suspected that he had got this disease from his father.

ការមន្ទិលក្នុងចិត្តមិនបានមួយខែផង គាត់ចាប់ក្តៅខ្លួនលេបថ្នាំលែងត្រជាក់។ ពេលនោះ ភ្នែកទាំងគូរបស់គាត់ ចាប់ឡើងពណ៌ក្រហមគួរឱ្យភ័យខ្លាចខ្លាំងណាស់។ ខណៈនោះ ជំងឺគាត់កាន់តែប្រែប្រួលពីមួយថ្ងៃទៅមួយថ្ងៃ ដោយភ្នែកបិទមិនជិត បាតដៃ បាតជើង ចាប់ផ្តើមស្ពឹកស្រពន់ខុសពីពេលមុន។ គាត់បារម្ភខ្លាំងណាស់ចំពោះខ្លួន និងអនាគតគាត់។ គាត់ឮគេនិយាយថា មានមន្ទីរពេទ្យមួយរបស់អង្គការស៊ីអូម៉ាល់ ស្ថិតនៅគៀនឃ្លាំង សម្រាប់ស្តារលទ្ធភាពជនពិការដោយសារជំងឺឃ្លង់។ គាត់បានសម្រាកព្យាបាលនៅទីនោះ អស់រយៈពេលប្រហែលជាបីខែ លោកគ្រូពេទ្យនៅគៀនឃ្លាំងក៏បានធ្វើសំណុំឯកសារ និង ប័ណ្ណគ្លីនិក បញ្ជូនឱ្យទៅព្យាបាលបន្តនៅឯស្រុកកញ្ច្រៀច ខេត្តព្រៃវែងវិញ។ គាត់ក៏មកបន្ត ការព្យាបាលនៅកញ្ច្រៀចរយៈពេលគ្រប់មួយឆ្នាំទើបឈប់។ ខណៈនោះស្បែកឡើងខ្មៅ ពិបាកមើលណាស់ លុះគាត់សម្រាកព្យាបាលរយៈពេលប្រហែលប្រាំមួយខែ រូបរាងពណ៌ សម្បុរក៏ដូចពីមុនវិញ។ បើទោះជានៅមានភ្នែកបិទមិនទាន់ជិត និងម្រាមដៃនៅស្ពឹក តែគាត់បានព្យាបាលជាសះស្បើយរួចហើយ ។

About a month later, he was worried about his skin lesion and it became true. He had fever all over the body. Even though he took some pills to stop the fever, it did not work. Day after day, his disease became worse and worse. His eyelids were red and could not close properly. He began to feel numbness in his palm and sole. He was very worried about himself and his future. He had information that there was a center in Phnom Penh, a rehabilitation center for disabled people affected by leprosy. He was admitted there and treated with Multi Drug Therapy (MDT) for three months then the doctor referred him back to Kanh Chreach District Health Department where he continued MDT for one year. While taking MDT his skin color became dark. But after he finished the treatment with MDT, in about six months, his skin color returned to normal. Although his eyelids do not close properly and his finger muscles remain numb but he is completely cured of leprosy.

គាត់ក៏បានរៀបការជាមួយនារីម្នាក់ដែលមានការយល់ដឹងអំពីជំងឺ និងគ្មានការរើសអើង។ នាងសុខចិត្តរៀបការជាមួយគាត់ដោយស្នេហ៍ពិត ។ សព្វថ្ងៃគាត់រស់នៅជាមួយប្រពន្ធឈ្មោះ **ហ៊ុល នាង** អាយុ ៣១ឆ្នាំ នាងបានបង្កើតកូនជាមួយគាត់ បាន២នាក់ គឺប្រុសម្នាក់ស្រីម្នាក់ មានរូបរាងគួរឱ្យស្រឡាញ់ណាស់ ។ គាត់បានរស់នៅជាមួយ ប្រពន្ធ-កូន រយៈពេលប្រាំមួយឆ្នាំមកហើយ តែពួកគាត់គ្មានសញ្ញាអ្វីគួរឱ្យសង្ស័យឡើយ។ ទោះបីជាគាត់មានបញ្ហាភ្នែក និងសាច់ដុំដៃខូចខាតដែលគេស្គាល់ថាជាសញ្ញាឃ្លង់ ក៏គាត់មិនតូចចិត្តនឹងព្រេងវាសនាកំហិតមកដែរ ព្រោះអតិថិជនរបស់គាត់ស្គាល់គាត់ និងមិនរើសអើងគាត់ទេ។ នៅពេលពួកគេស្តាប់វិទ្យុ មើលទូរទស្សន៍ តែងតែប្រទះឃើញកម្មវិធីប្រយុទ្ធនឹងជំងឺហង់សិនថាមិនមែនជាជំងឺស្នូរពូជទេ គឺជាជំងឺឆ្លង ជាប្រភេទបាក់តេរីដែលគេអាចព្យាបាលជា មួយរយភាគរយ។ ហើយថ្នាំច្រើនមុខ（MDT）ពេលនេះមានប្រសិទ្ធភាពណាស់ គឺគ្រាន់តែអ្នកជំងឺលេបតែថ្នាំប្រហែលមួយសប្តាហ៍អ្នកជំងឺលែងចម្លងទៅអ្នកដទៃហើយ។

He decided to get married with a girl who had knowledge and understood about the disease without discrimination. She agreed to get married him with her true love. At present, he is living with his wife, Hol Neang, 31 years old. They have two children, one son and one daughter. Their both children have good physical features. He has lived with his family for six years but there is no leprosy skin sign on him. Even though, he has problems with his eyes, and his finger muscles are partly wasted, which people know are symbols of leprosy, but he is not disappointed with his destiny. All his clients understood and never discriminated him. When they listened to the radio or watch TV, they always heard or saw the health promotion from National Leprosy Elimination Program explain that leprosy is not hereditary but it is only a mildly infectious disease. It is caused by a kind of bacteria, and the disease can be cured 100% by Multi Drug Therapy (MDT). MDT is a very effective medicine. If people have leprosy, just take MDT, it will cure leprosy and the transmission to other people is prevented.

សព្វថ្ងៃនេះគាត់មានជំនាញហើយគាត់បានដំណើរការប្រកបមុខរបរជាមួយនឹងការខ្ចីប្រាក់ពីអង្គការគាំទ្រ។ គាត់បានសងប្រាក់ដែលខ្ចីនោះទៅអង្គការរួចរាល់ហើយ គាត់បានប្រាក់ចំណេញជាច្រើនពីប្រាក់កម្ចីនេះ ។ គាត់មានមុខរបរ និងធ្វើការងារដូចអ្នកដទៃក្នុងភូមិដោយគ្មានការរើសអើង។



Now, he has a skill, and he is running his business well with a loan from a supportive organization. He has already paid back his loan to the organization. He has been much benefitted from this loan. He has a job and work as anybody else in the village without discrimination.



***គម្រោងរបស់ខ្ញុំគឺជាកសិករចិញ្ចឹមមាន់ និងជាអ្នកមិនពឹងដោយខ្លួនឯង ខ្ញុំមានភាពពិការខ្លះដោយសារជំងឺឃ្លង់ ប៉ុន្តែខ្ញុំមានសិទ្ធិរស់នៅ និងមានសេចក្តីសង្ឃឹមក្នុងជីវិត ។***

ខ្ញុំចង់ដាក់ពាក្យខ្ចីថវិកាខ្លះពីអង្គការ ដើម្បីចាប់ផ្តើមដំណើរការ តាមគម្រោងរបស់ខ្ញុំជាកសិករចិញ្ចឹមមាន់ ខ្ញុំលែងចង់រស់នៅដោយពឹងផ្អែកលើបងខ្ញុំតទៅទៀតហើយ ។

***My plan wants to be a poultry farmer and lives independently. I have some physical impairment due to leprosy but I have the rights to live and live in hopeful.***

I want to get some loans from an organization to start implementing my plan as a poultry farmer. I don't want to live and depend on my brother forever.

គ្មាននរណាម្នាក់ដឹងពីអនាគតទេ ខ្ញុំមិនតូចចិត្តនឹងព្រហ្មលិខិត ដែលកំណើតឱ្យខ្ញុំកើតក្នុងត្រកូលកសិករក្រីក្របំផុត ហើយអ្នកម្តាយរបស់ខ្ញុំជាអ្នកកើតជំងឺឃ្លង់ទៀត ។

កាលពីកុមារភាព ខ្ញុំបានចូលរៀននៅសាលាបឋមសិក្សាគោក ។ ខ្ញុំរៀននៅទីនោះបីឆ្នាំ ខ្ញុំបានឈប់រៀនដោយសារ ឪពុកម្តាយបានស្លាប់ចោលតាំងពីខ្ញុំអាយុ១០ឆ្នាំម្ល៉េះ ។ ខ្ញុំគឺជាកូនពៅក្នុងចំណោមបងប្អូន៤នាក់ ដែលមានបងប្រុស២នាក់ និងស្រី២នាក់ ។ ក្នុងឆាកជីវិតជាកូនកសិករក្រីក្រខិតខំត្រដររស់ដោយក្តីលំបាកបំផុត គឺធ្វើស្រែពឹងលើទឹកភ្លៀង ។ តាំងពីឪពុកម្តាយស្លាប់ទៅ ខ្ញុំក៏សម្រេចចិត្តឈប់រៀន ហើយមករស់នៅជាមួយបងប្រុសបង្អស់ តែគាត់ក៏មានកូនច្រើន ជីវភាពពឹងតែលើដីស្រែប្រហែលជាពីរហិកតាតែប៉ុណ្ណោះ ។ នៅឆ្នាំ១៩៩៤ ខ្ញុំដឹងដែរថាមានចេញស្នាមសនៅក្បាលពោះ ខ្ញុំក៏ពុំបានជាចាប់អារម្មណ៍នឹកដល់ថាជាជំងឺឃ្លង់ទេ ព្រោះកាលម្តាយខ្ញុំកើតជំងឺនេះ ខ្ញុំនៅតូចណាស់ ។ លុះពេលធំដឹងក្តី គាត់បានបញ្ចប់ការព្យាបាល តែគួរឱ្យសោកស្តាយគាត់មានភាពពិការខ្លះរួចទៅហើយ ។

No one knows the future. I am not disappointed with my destiny even though I was born into a poor farmer's family and my mother had leprosy.

When I was a child, I studied at Kok primary school. I studied there for three years. I had to stop going to school because my father passed away when I was only 10 years of age. I am the last daughter among four children, two boys and two girls. A farmer's life was very difficult because we do farming dependent on the rain. I lived a very difficult condition while my parents passed away; I stopped studying in grade three and lived with my eldest brother who also had a large family. We lived depend on the two hectares of rice field. In 1994, I had a spot on my abdomen, and I didn't think that I had leprosy. I was young when my mother had leprosy. When I grew up, she had already cured her leprosy but unfortunately she had some disabilities.

ខ្ញុំសូមជម្រាបផងដែរ  ក្នុងពេលដែលនាងខ្ញុំមានរោគសញ្ញាចេញដំបូងនៅក្បាលពោះនោះ កម្មវិធីជាតិប្រយុទ្ធប្រឆាំងនឹងជំងឺហង់សិន បានធ្វើយុទ្ធនាការស្រាវជ្រាវរកជំងឺឃ្លង់ជាច្រើនលើកច្រើនសារដែរ តែខ្ញុំព្យាយាមលាក់បាំងរហូតដោយមិនឱ្យអ្នកណាម្នាក់ដឹងថាខ្ញុំមានរោគសញ្ញាឃ្លង់ឆ្លងពីម្តាយទេ ។ ក្នុងពេលយុទ្ធនាការនោះ ពួកមេក្រុម ប្រធានភូមិ មេឃុំ និងនាយកសាលា បានបង្ហាញសញ្ញាគ្រប់ៗគ្នាឱ្យតែនរណាម្នាក់មានស្នាកស្នាមនៅលើស្បែក ត្រូវតែទៅពិនិត្យដោយភ្នាក់ងារសុខាភិបាលជំនាញ ក្នុងគោលបំណងស្រាវជ្រាវរកជំងឺឃ្លង់ ។ ពេលវេលាចេះតែវិលទៅមុខជានិច្ច...! រីឯជំងឺរបស់ខ្ញុំក៏ចាប់ផ្តើមចេញស្នាកស្នាមពេញតែខ្លួន ។ ចំណែកដៃទាំងពីររបស់ខ្ញុំ ចាប់ផ្តើមស្ពឹកលែងដឹងក្តៅត្រជាក់ មានពេលខ្លះដាំបាយ ដោយប្រញាប់ពេកខ្ញុំចាប់កាន់ឆ្នាំងដែលក្តៅដោយមិនទ្រាប់កំណាត់ (ក្រណាត់) ក៏ចាប់កាន់បានដែរ ។ ចំពោះជើងទាំងពីររបស់ខ្ញុំក៏ចាប់ស្ពឹកដូចពាក់ស្រោមជើងអញ្ចឹង ។ថ្ងៃមួយខ្ញុំមានការពិបាកក្នុងខ្លួនជាខ្លាំងដោយមានការឈឺចាប់ និងគ្រុន បងប្រុសខ្ញុំបាននាំខ្ញុំមកសម្រាកនៅមន្ទីរពេទ្យស្រុកស្វាយអន្ទរហូតដល់បាត់គ្រុន ។ គាប់ជួនពេលនោះអង្គការស៊ីអូម៉ាល់ចុះធ្វើការបានជួបរូបខ្ញុំ ក៏យកទៅព្យាបាលនៅគៀនឃ្លាំង ។

When I had a skin sign on my abdomen, there was National Leprosy Elimination Program campaign. In that campaign, village chiefs, commune chiefs and school directors showed the leprosy skin signs to all people and told anyone who had that skin sign should came to consult health professional. I didn't go to show them. I kept myself away from people because I didn't want people to know that I had leprosy from my mother. Time passed quickly. Eventually my body was totally covered with leprosy skin patches. My two hands became numb and even though I touched a hot pot I did not feel it. My feet became numb and it felt as if I were wearing a pair of thick socks. One day, I had a serious trouble with pain and fever. My brother brought me to Svay Anthor district hospital. There the doctor diagnosed me and I got better after treatment. At that time, CIOMAL organization staff visited my village and met me. They brought me to Leprosy Rehabilitation Center in Phnom Penh.

នៅក្នុងមន្ទីរពេទ្យគៀនឃ្លាំង ខ្ញុំបានឃើញអ្នកជំងឺយ៉ាងច្រើនដេកព្យាបាលនៅទីនោះ ភាគច្រើនគឺជាអ្នកជំងឺមានភាពពិការ ។ ខណៈនោះប្រហែលជានៅក្នុងឆ្នាំ២០០៥ ជើងទាំងពីររបស់ខ្ញុំមានការឈឺចាប់យ៉ាងខ្លាំង ខ្ញុំពុំអាចដើរបានឡើយ ពេលនោះហើយដែលទឹកភ្នែកខ្ញុំចាប់ហូរដោយមិនដឹងខ្លួន ខ្ញុំគិតថា នេះជាការដាក់ទណ្ឌកម្ម របស់ព្រះជាម្ចាស់ឬ? តែក្រោយមកខ្ញុំបានយល់ច្បាស់ថាវាជាការគិតខុស គឺខ្ញុំទើបតែបានឆ្លងមេរោគម្យ៉ាង..!!! ខ្ញុំមិនបន្ទោសម្តាយខ្ញុំ ឬព្រះជាម្ចាស់ទេ ព្រោះពេលនេះវាជ្រុលហួសទៅហើយ គឺត្រូវបណ្តោយទៅតាមកម្មវាសនាទៅចុះ ។ ខ្ញុំគេងក្នុងមន្ទីរពេទ្យគៀនឃ្លាំងបានប្រហែលជាមួយខែ គ្រូពេទ្យនៅគៀនឃ្លាំងក៏បានបញ្ជូននាងខ្ញុំមកធ្វើការវះកាត់នៅមន្ទីរពេទ្យកាល់ម៉ែត្រ ពេលនោះគ្រូពេទ្យជំនាញធ្វើការវះកាត់តែជើងឆ្វេងមួយប៉ុណ្ណោះ ។ ខ្ញុំត្រូវវិលមកគេងសម្រាកក្នុងមន្ទីរពេទ្យគៀនឃ្លាំង បន្តរហូតដល់អាចដើរបាន ទើបវិលត្រឡប់មកផ្ទះនៅឯស្រុកស្វាយអន្ទរវិញ ។

In the Center, I saw many leprosy patients under various treatments. Most of them had severe disabilities. In 2005, I had a severe pain in my both feet, and I could not walk. I cried and my tear dropped. I first thought it was a punishment from the gods or what? But when I thought deeply, I came to realize that it was my own fault. I had got infected with one kind of bacteria. I didn't blame the god nor my mother. I thought let it pass to the end of my life. I returned to Leprosy Rehabilitation Center for treatment. After one month when my reaction subsided, the doctor of the center sent me to Calmette Hospital for reconstructive surgery by professional surgeons. I stayed there until my feet healed. Finally I was able to come back my homeland at Svay Antor District.

ខ្ញុំត្រឡប់មកភូមិកំណើតវិញ ខ្ញុំសប្បាយចិត្តណាស់ ព្រោះខ្ញុំអាចដើរបាន និងគ្មានការរើសអើងពីនរណាម្នាក់ឡើយ ។ ខ្ញុំរស់នៅជាមួយបងប្រុសដដែល តែសព្វថ្ងៃគ្មានមុខរបរអ្វីទេ អារម្មណ៍ខ្ញុំនឹកចង់បង្កើតមុខរបរអ្វីមួយដោយខ្លួនឯង គឺចង់ចិញ្ចឹមមាន់ គ្រាន់បានប្រាក់កាសខ្លះសំរាប់ចិញ្ចឹមជីវិត។ ខ្ញុំមានភាពពិការខ្លះ តែខ្ញុំមានសិទ្ធិក្នុងការរស់នៅ និងមានឆន្ទះក្នុងការរស់នៅផងដែរ ខ្ញុំចង់សំណូមពរ ចង់ខ្ចីប្រាក់កាសខ្លះ ដើម្បីធ្វើដើមទុនក្នុងការប្រកបមុខរបរចិញ្ចឹមមាន់។ ខ្ញុំមិនចង់រស់នៅ ដោយពឹងផ្អែកលើបងប្រុសរបស់ខ្ញុំទាំងស្រុងបន្តទៅទៀតទេ ។



I was very happy when I came back home. I could walk as before, and I found no discrimination from the villagers. Currently, I am living with my brother because I do not have a job to help myself. I want to have my own job.  I want make my own living by raising chicken. I have some disabilities but I have rights to live and have a willing to live. I want to apply for some loan from an organization to start my business as a poultry farmer. I don't want to live depend on my brother anymore.



សព្វថ្ងៃយើងមានកូនម្នាក់ ហើយមុខរបររបស់យើងខ្ញុំ ដំណើរការបានល្អណាស់ យើងខ្ចីប្រាក់បន្ថែមទៀត ដើម្បីពង្រីកមុខរបរ ។ យើងមានភាពពិការខ្លះ ប៉ុន្តែយើងមានស្នេហ៍ពិត និងរស់នៅយ៉ាងរីករាយជាមួយគ្រួសារ ។

***Today we have one baby. Our business is running well, and we get another loan from organization to expand our business. We have some physical impairment but we have a true love and live happily in family.***

អតីតកាលពោរពេញទៅដោយភាពល្វីងជូរចត់ រកអ្វីមកថ្លែងពុំបាន ឪពុកម្ដាយគឺជាអ្នកខេត្តកំពង់ឆ្នាំង ពួកគាត់រៀបការក្នុងឆ្នាំ១៩៧៨ គឺនៅក្នុងរបបប៉ុលពត ។ បន្ទាប់ពីរបបអប្រិយនេះរលំរលាយទៅ គាត់ទាំងពីរនាក់គ្មានដើមទុនអ្វីរកស៊ី ក៏នាំគ្នាមករស់នៅស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ដើម្បីធ្វើស្រែចំការ និងដើររកបន្លែ ផ្លែឈើព្រៃ សំរាប់លក់ព្រាន់ចិញ្ចឹមជីវិត ។

ថ្ងៃមួយនៅឆ្នាំ១៩៨៦ កាលនោះនាងខ្ញុំមានអាយុប្រហែល៦ឆ្នាំ ហើយប្អូនប្រុសរបស់ខ្ញុំមានអាយុតែ៤ឆ្នាំប៉ុណ្ណោះ គឺជាថ្ងៃដ៏អាក្រក់ ពួកគាត់ទាំងពីរនាក់បាននាំគ្នាទៅរកជីកទំពាំង ក៏ដើរជាន់មីនស្លាប់ទាំងពីរនាក់ទៅ ។ តាំងពីពេលនោះមក ជីវិតនាងខ្ញុំនិងប្អូនរស់នៅជាក្មេងកំព្រាអនាថា រស់នៅដោយសារអ្នកជិតខាងគេជួយចិញ្ចឹម ។ នៅចុងឆ្នាំ១៩៨៨ ដោយខ្វះខាតខោអាវដណ្ដប់រាងកាយ ប្អូនប្រុសខ្ញុំស្លៀកពាក់តែខោខ្លីកញ្ចាស់ៗគាប់ជួនឆ្នាំនោះ ជារដូវគ្រុនឈាមរាតត្បាតពេញទាំងខេត្ត បណ្ដាលឱ្យប្អូនប្រុសខ្ញុំមានជំងឺគ្រុនឈាមបានស្លាប់បាត់ទៅ ។

In the past, my life was indescribable. It was full of bitterness. My parents were living in Kampong Chhnaing province. They got married in 1978 during the Pol Pot regime. After this regime had been collapsed, my parents have nothing so they decided to live in Baribo District, Kampong Chhnaing Province. They planted vegetables, picked wild-fruits to sell for supporting family.

One day in 1986, my parents went to dig bamboo shoots and stepped on land mine when I was six years old and my younger brother was four years old. Unfortunately both of them had died. Since that time, we lived as orphaned-children and living by neighbors give food and other equipments. At the end of 1988, we were still living in a complicated situation. We didn't have even cloth to wear. On that year, there were dengue fever epidemic and spreaded all over the province. Unlucky, my brother was contagious that disease and died.

បន្ទាប់ពីប្អូនប្រុសកម្សត់បានស្លាប់ទៅ នាងខ្ញុំសែនស្រណោះខ្លួនណាស់ ដោយរស់នៅតែម្នាក់ឯងក្រោមដំបូលខ្ទមរយីករយាក គឺស្លឹកត្នោតដែលប្រក់ត្រូវចាស់ធ្លុះធ្លាយអស់ ។ នាងខ្ញុំកម្សត់ណាស់ មួយថ្ងៃៗដើរបេះស្លឹកបាសលក់ បានប្រាក់បន្តិចបន្តួចគ្រាន់តែបបរហូប ជាមួយកូនត្រី ក្ដាម ខ្យង ដែលបានជញ្ជាត់។ ពេលខ្លះឆ្លៀតរើសស្លឹកត្នោតយកមកដេរ រកចាស់ម៉ុជិតខាងជួយប្រក់ព្រំទៀតផង ។

ចូលមកដល់ឆ្នាំ១៩៨៩ ស្រាប់តែលោត់មើលពោះ ឃើញលេចចេញជាស្នាមសមួយចម្លែក គឺកន្លែងចេញនោះ មានការបាត់បង់ញាណដឹង តែវាគ្មានផលរំខានអ្វីទេ។ ជីវិតជាក្មេងកំព្រា ប្រឹងត្រដររស់នៅដោយខ្លួនឯង ពុំបានជាចាប់អារម្មណ៍ទេ ស្នាមនោះចេះតែរាលដាលទៅៗ ហើយក៏លេចចេញស្នាមថ្មីជាបន្តទៅទៀត។ ថ្ងៃមួយប្រហែលជានៅក្នុងឆ្នាំ១៩៩២ នាងខ្ញុំក៏ចាប់មានជំងឺគ្រុនក្ដៅ ឈឺដៃ ឈឺជើង ចុកចាប់ក្រៃលែង។ ខណៈនោះ ខ្ញុំមានការអស់សង្ឃឹមយ៉ាងខ្លាំង ព្រោះជីវិតជាក្មេងអនាថាវេទនាពេកស់។ ក្នុងពេលដ៏សែនលំបាកនោះ ក៏មានលោកយាយម្នាក់មកជួយកំដរដែរ គាត់បានយកបបរមកឱ្យខ្ញុំញ៉ាំ និងជួយណែនាំខ្ញុំឱ្យខំប្រឹងតស៊ូរស់នៅតទៅទៀត ព្រោះថាវាសនាមនុស្សមើលមិនឃើញទេ ឆ្អឹងនៅក្នុងសាច់ តែអនាគតមិនអាចទស្សន៍ទាយបានឡើយ ។

After my brother had died, I lived alone under a palm leaf shelter which was leaking everywhere. I lived by selling green vegetable leaves. I had only porridge with small fish which I caught by myself to eat. When I had free time, I collected palm-tree leaves to replace the roof of my leaking shelter.

In 1989, I saw a strange white skin patch on my abdomen. It was insensitive and was not itching so I did not worry about it. As an orphan, I tried to live independently, and I only concentrated on my living and did not care about my skin patch. Later, the skin patch became more and more and appeared new skin patches over my body. One day in 1992, I had a mild fever, and my both hands and feet were numb. I was in hopeless; suddenly there was an old lady came to give a bowl of porridge and advised me, "You must fight your destiny."

វាជាសំណាងមួយរបស់ខ្ញុំដែរ នៅពេលដែលរោគាខ្ញុំកំពុងតែធ្ងន់ធ្ងរនោះ លោកគ្រូភូរ៉ាក៏ជិះរថយន្តជាមួយលោកគ្រូ ថ្នាក់ជាតិពីរនាក់ទៀត ចុះមកសួរសុខទុក្ខខ្ញុំ ។ លោកគ្រូភូរ៉ាមានសេចក្តីស្រណោះដល់រូបខ្ញុំណាស់ គាត់បានទិញសេរ៉ូមមកព្យួរឱ្យខ្ញុំមួយកំផ្លោក រួចលោកបានធ្វើប័ណ្ណគ្លីនិក ចាប់ព្យាបាលថ្នាំច្រើនមុខ (MDT)ឱ្យខ្ញុំភ្លាម ។ នៅពេលព្យាបាលនោះ គឺខ្ញុំមានអាយុ១២ឆ្នាំហើយ ការព្យាបាលរបស់ខ្ញុំមានរយៈពេល២ឆ្នាំ ដោយបានទទួលទាំងថ្នាំ និងស្បៀងអាហារបរិភោគ ពីកម្មវិធីស្បៀងអាហារពិភពលោកទៀតផង ។ ក្រោយពីបានព្យាបាលចប់ ខ្ញុំរស់នៅតាមធម្មតាបន្តទៅទៀត រហូតដល់ឆ្នាំ២០០៧ នាងខ្ញុំក៏ជួបជំងឺប្រតិកម្មយ៉ាងធ្ងន់ធ្ងរ គឺដេកគ្រុននៅនឹងកន្ទេល ។ ពេលនោះខ្ញុំគេងបង្ហូរទឹកភ្នែកជោគខ្នើយ ថាជីវិតខ្លួនឯងពេលនេះត្រូវចប់ហើយ ។ កំពុងតែគេងអស់សង្ឃឹម ស្រាប់តែរថយន្តខាងកម្មវិធីប្រយុទ្ធប្រឆាំងនឹងជំងឺហង់សិន បានមកឈប់មុខខ្ទមខ្ញុំតែម្តង ។ ខំប្រឹងក្រោកអង្គុយ ស្រាប់តែស្រមោលលោកគ្រូភូរ៉ានាំគ្នាពីរបីនាក់ចុះមកសាកសួរខ្ញុំដោយយកចិត្តទុកដាក់ជាទីបំផុត ។

It was my luckiness while I was seriously sick. There were Mr. Phoura, Provincial Leprosy Supervisor, came to my house with two other men who were doctors from National Leprosy Elimination Program. Mr. Phoura told me that I had leprosy. He felt pity toward me and injected a bottle of saline solution and gave me a blister of Multi Drug Therapy (MDT). During that time, I was only 12 years old, and it took me two years for treatment. During the treatment, I was supported food by World Food Program. After I finished my treatment, I was able to live as normal person. In 2007, I had a serious reaction again. I had to stay on the bed and could not do anything. I thought my life will be finished in this time so my tears were dropping ceaselessly. While I was in hopeless, there was a car of National Leprosy Elimination Program came to my shack. I tried to get up, and I saw Mr. Phoura came with other person and looked carefully at me.

ក្រោយពីពួកគាត់បានធ្វើការពិគ្រោះគ្នាបន្តិចមក ក៏សម្រេចចិត្តបញ្ជូនខ្ញុំមកកាន់មន្ទីរពេទ្យគៀនឃ្លាំងភ្នំពេញ។ ខ្ញុំតេងសម្រាកព្យាបាលនៅទីនោះអស់រយៈពេលបីខែ ទើបលោកគ្រូពេទ្យសម្រេចចិត្តបញ្ជូននាងខ្ញុំមកធ្វើការវះកាត់ កែលម្អនៅក្នុងមន្ទីរពេទ្យកាល់ម៉ែត បានមួយសប្តាហ៍ ទើបឱ្យរូបខ្ញុំត្រឡប់មកមន្ទីរពេទ្យគៀនឃ្លាំងវិញដើម្បីធ្វើការព្យាបាលដោយចលនាបន្តទៀត។ ក្នុងរយៈពេលនៃការព្យាបាលដោយចលនានោះហើយ ដែលនាងខ្ញុំបានជួបកម្លោះសង្ហារម្នាក់ ឈ្មោះ *វ៉ាន់ ពុត* ដែលកាលនោះ គាត់ទើបតែមានអាយុ២០ឆ្នាំតែប៉ុណ្ណោះ និងមានភាពពិការ ដោយសារជំងឺឃ្លង់ដូចជានាងខ្ញុំដែរ ។ យុវជន វ៉ាន់ ពុត គាត់ពិការតែដៃឆ្វេង និងស្ពឹកជើងឆ្វេង។ ហេតុតែនិស្ស័យពីអតីតជាតិក៏មិនដឹង នៅពេលដែលយើងទាំងពីរនាក់ហាត់ធ្វើចលនា យើងចេះតែសម្លឹងគ្នាទៅវិញទៅមក រហូតដល់មានអនុស្សាវរីយ៍យ៉ាងច្រើន ដែលមិនអាចបំភ្លេចបានឡើយ ។ លុះដល់ពេលកំណត់នៃការព្យាបាល យើងទាំងពីរក៏ចេញពីមន្ទីរពេទ្យត្រឡប់មកខ្ទម នៅឯស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ព្រមទាំងរកចាស់ទុំក្នុងភូមិ ជួយសែនព្រេនបន្តិចបន្តួចបានគ្នាជាប្តីប្រពន្ធ។ អង្គការស៊ីអូម៉ាល់ ជួយឧបត្ថម្ភប្រាក់កាសខ្លះ ធ្វើដើមទុនរកស៊ីលក់ចាប់ហួយបន្តិចបន្តួច ។

After they had discussed for a while, they decided to send me to Leprosy Rehabilitation Center in Phnom Penh. I had stayed there for three months and then the doctor sent me to Calmette hospital for hands and feet reconstructive surgery. One week later, I was sent back to Leprosy Rehabilitation Center for physical therapy treatment. While I was treatment at the Center, I met one man, Mr. *Vann Put*, 20 years old, and he also had disability due to leprosy as me. He had clawed fingers on the left hand and his left foot had lost sensation. While we were doing exercises in physical therapy room, we took a look each other until we fall in love. After we had completely cured our leprosy, we came back home together. We had a small wedding ceremony by inviting elderly people in the village to be the witness. CIOMAL Organization now helped us to run a small grocery shop.

មិនត្រឹមតែប៉ុណ្ណោះ ប្តីខ្ញុំឆ្លៀតទៅធ្វើជាកម្មករនៅខេត្តកោះកុង ដើម្បីរកប្រាក់ចំណូលបន្ថែមទៀត ពីរបីខែទើបបានត្រឡប់មកផ្ទះម្តង ។ សព្វថ្ងៃ ខ្ញុំមានកូនស្រីមួយជាចំណងដៃ ហើយអង្គការស៊ីអូម៉ាល់ ឃើញយើងខ្ញុំខ្វះខាតក៏អោយខ្ចីដើមទុនបន្ថែមទៀតដើម្បីរកស៊ី ។ ខ្ញុំទាំងពីរ ពិការមែនពិត តែទឹកចិត្តស្មោះត្រង់រវាងគ្នានឹងគ្នា រស់នៅយ៉ាងសុខសាន្តបំផុត ។ ខ្ញុំបានធ្វើការសម្ភាសន៍ជាច្រើនលើកមកហើយ បាននិយាយពីជីវិតពិតរបស់ខ្ញុំ ជាពិសេសក្រោយពេលដែលខ្ញុំចូលរួមការអំពាវនាវជាសកលក្នុងឆ្នាំ២០០៧ ដើម្បីបញ្ឈប់ការរើសអើង និងការមាក់ងាយចំពោះជនរងគ្រោះដោយសារជំងឺឃ្លង់ ។



Moreover, my husband also worked in Koh Kong province in order to get more income and will back home in every few months. Nowadays we have one baby, and CIOMAL Organization also gave us another loan to support our business. Even we are disabled people but we loved and full respect each other. I have had many interviews and shared my true-story to all people. Especially I had also joined the Global Appeal 2007 to End Stigma and Discrimination against People Affected by Leprosy.



*ខ្ញុំបានរស់នៅជាមួយភាពពិការដោយសារជំងឺឃ្លង់ អស់រយៈពេលម្ភៃឆ្នាំមកហើយ ប៉ុន្តែ ខ្ញុំគ្មានការអៀនខ្មាស់ទេ ពីព្រោះគេរាល់គ្នាទទួលស្គាល់ខ្ញុំ ដោយគ្មានការរើសអើង ។*

***I have lived with disability due to leprosy for 20 years ago, but I am not shy because people have accepted me without any discrimination.***

ខ្ញុំមានឪពុកម្តាយជាអ្នកធ្វើស្រែ រស់នៅក្នុងស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។ កាលពីកុមារ សិក្សានៅសាលាបឋមសិក្សាស្រែថ្មី ហើយបន្តការសិក្សានៅវិទ្យាល័យខេត្តកំពង់ឆ្នាំង រហូតដល់ប្រលងជាប់សញ្ញាប័ត្រឌីប្លូម រួចបានប្រលងចូលនគរបាល។ កាលពីកុមារ ខ្ញុំមានការតស៊ូណាស់ ដើរទៅរៀនជិវាប់គីឡូម៉ែត្រ។ ក្នុងសម័យនោះការហូបចុកមិនគ្រប់គ្រាន់ទេ ប៉ុន្តែនៅតែព្យាយាមប្រឹងប្រែងរៀនសូត្រ រហូតបានប្រលងចូលរៀនអនុវិទ្យាល័យរួចបញ្ចប់ការសិក្សានៅទីរួមខេត្តកំពង់ឆ្នាំង។ ពេលចូលរៀនផ្នែកនគរបាល គេបញ្ជូនឱ្យទៅរៀននៅរាជធានីភ្នំពេញចំនួនប្រាំមួយខែ ហើយចេញធ្វើការមានឋានៈ ត្រឹមតែជាពលបាលត្រីតែប៉ុណ្ណោះ។ លុះចេញធ្វើជានគរបាលបានមួយឆ្នាំឪពុកម្តាយក៏ផ្សំផ្គុំរៀបការជាមួយនារីម្នាក់ឈ្មោះ***នាង ចាន់ថា*** រស់នៅភូមិស្រុកជាមួយគ្នា។ សម័យនោះ មានការអុកឡុកពីភាគីខ្មែរម្ខាងទៀតខ្លាំងក្លាណាស់ សង្គ្រាមក៏ចេះតែអូសបន្លាយទៅមុខគ្មានថ្ងៃនឹងបញ្ចប់ តែពលបាលត្រីរូបនេះ នៅតែទ្រាំតស៊ូជានិច្ច មិនចុះចាញ់នឹងព្រហ្មលិខិតឡើយ ។ ក្រោយពេលរៀបការបានមួយឆ្នាំពេលមួយនោះខ្ញុំបានស្រាតខោវែងចេញ ស្រាប់តែឃើញស្នាមពីរនៅនឹងភ្លៅខាងស្តាំ។

My parents are farmers who lived in Rolea Barear District Kampong Chhnang Province. When I was a child, I studied at Sre Thmey Primary School and continued to study at Kampong Chhnang High School. While I had finished junior high school, I took extrance-exam to study at police school. I was a good child, and I walked several kilometers to school every day. Sometimes I didn't have any food to eat but I still wanted to study. I finished junior high school in Kampong Chhnang Province. After I had completed my study at police school; I was sent to study in Phnom Penh for six months, and I then worked as a sergeant. After working for one year, I was arranged to get married to Miss *Neang Chantha* who lived in the same village. During that time, there was a civil war between the government forces and Pol Pot military. To be a sergeant, I never gave up my job and fight with the destiny. After got marriage one year, I had seen two skin patches on my right thigh when I took off my trousers.

ដំបូងខ្ញុំស្មានតែស្រែង តែស្នាមនោះគ្មានធ្វើឱ្យរំខានទាល់តែសោះ ព្រោះវាគ្រាន់តែបាត់បង់ញ្ញាណដឹងបន្តិចបន្តួច ។ ដោយសារស្រុកទេសកើតសង្គ្រាមផងនោះ ទើបខ្ញុំពុំបានជាចាប់អារម្មណ៍ក្នុងព្យាបាល បណ្តោយឱ្យស្នាមនោះចេះតែរីកធំឡើងៗ ហើយចេញថ្មីជាបន្តបន្ទាប់ ។ នៅឆ្នាំ១៩៨៨ ស្លាកស្នាមនៃស្បែកខ្ញុំទៅជាហើម ក្រហម ក្តៅ ខ្ញុំបានគ្រុនយ៉ាងខ្លាំង ហើយម្រាមដៃខ្ញុំបានឡើងក្រញ៉ង់ ។ វាជាសំណាងល្អដែរមានមិត្តភ័ក្រម្នាក់ឈ្មោះភូរ៉ា ថ្ងៃមួយចំពេលគាត់មកលេងផ្ទះនិងសួរសុខទុក្ខមិត្តភ័ក្រក្នុងភូមិជាមួយគ្នា ព្រោះជាពេលវិស្សមកាលរបស់គាត់ ដោយសារភូរ៉ាជាសិស្សគិលានុបដ្ឋាកមធ្យម ពេលគាត់បានឃើញខ្ញុំ គាត់ក៏សង្ស័យថា ខ្ញុំមានរោគសញ្ញាឃ្លង់ ភ្លាមនោះក៏បញ្ជូនខ្ញុំទៅព្យាបាលនៅមន្ទីរពេទ្យខេត្តកំពង់ឆ្នាំង។ ខ្ញុំសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ បានមួយសប្តាហ៍ គេក៏បញ្ជូនខ្ញុំទៅស្ថានីយ៍អនាម័យខេត្ត ផ្នែកប្រយុទ្ធនឹងជំងឺហង់សិន។ ពេលនោះគ្រូពេទ្យជំនាញក៏ពន្យល់ណែនាំខ្ញុំ ឱ្យលេបថ្នាំរយៈពេលពីរឆ្នាំ។ ពេលកំពុងព្យាបាលដោយប្រើថ្នាំច្រើនមុខ ខ្ញុំមិនដែលខកខានក្នុងការងារទេ ពេលនោះថ្នាក់លើបានតម្លើងឋានន្តរសក្តិដល់ខ្ញុំជាពលបាលឯក ។

At first, I thought it was a ring worm because it didn't make me hurt but I feel a little loss of sensation. Due to the civil war, I didn't care about those skin patches so they grew up bigger and bigger and also appeared other new skin patches. In 1988, my skin lesions became swollen, red and warm. I have a serious fever, and my fingers were clawed. Luckily, one day my friend, Phoura, is a nurse's student that came to visit me. He suspected that my skin lesions are leprosy so he immediately sent me to Kampong Chhnaing Provincial Hospital. I stayed in the hospital for a week and then I was sent to provincial hygiene station in leprosy section. Doctors advised me to take medicine, MDT, for two years. While I was using the leprosy medicine, I was promoted to be the rank of sergeant major.

ចំណែកឯភរិយាខ្ញុំវិញ ក៏ខំប្រឹងប្រែងធ្វើស្រែ ចិញ្ចឹមជ្រូកមិនឱ្យទំនេរទេ។ លុះពេលកូនគ្រប់អាយុចូលរៀន ខ្ញុំក៏បាននាំកូនទៅចុះឈ្មោះចូលរៀន ព្រោះយល់ថា មានតែចំណេះវិជ្ជានេះទេ ដែលអាចធ្វើឱ្យមនុស្សថ្លៃថ្នូរបាន។ រីឯកូនៗរបស់ខ្ញុំ ទាំងពីរនាក់ម្នាក់រៀនដល់មហាវិទ្យាល័យ ឯកូនម្នាក់ទៀត រៀនដល់ថ្នាក់ទី១២។ សព្វថ្ងៃ ខ្ញុំឡើងឋានន្តរសក្តិជាអនុសេនីយ៍ទោហើយ ចំណែកខ្ញុំនិងភរិយា នៅតែរួមដៃគ្នាតស៊ូជានិច្ចរហូតមានផ្ទះធំទ្រនំខ្ពស់ មានដីស្រែរាប់សិបហិកតា និងមានម៉ូតូសេរីថ្មីជិះទៀតផង។ ថ្វីត្បិតតែខ្ញុំពិការម្រាមដៃពិតមែន តែខ្ញុំគ្មានការខ្មាស់អៀនអ្វីទេព្រោះគ្មានអ្នករើសអើង។



My wife wasn't idle either; she worked hard on feeding pig and did farming. When my both children were enough age, I will bring them to enroll to study. I believe that there was only education that can make their future life better. One of my children studies at a university and another one studies in grade 12. Now I have been promoted again as a first lieutenant, and my wife and I work hard together to earn money. Nowadays, we have a big house, many hectares of rice fields and new series of motorbikes. Even I have clawed fingers but I am not ashamed because there is no discrimination against me.



ខ្ញុំជាជនពិការមែនពិត ប៉ុន្តែរស់នៅដោយសេចក្តីថ្លៃថ្នូរ ខ្ញុំបានទទួលការគាំទ្រឱ្យខ្ចីប្រាក់ពីអង្គការមួយ សម្រាប់ចិញ្ចឹមមាន់ ។ ខ្ញុំជាអ្នករត់ម៉ូតូឌុប ខ្ញុំមានផ្ទះមួយ និងរស់នៅជាមួយគ្រួសារដោយគ្មានការរើសអើង ខ្ញុំពេញចិត្តនឹងរៀបរាប់អំពីជីវិតពិតរបស់ខ្ញុំចែកជូនអ្នកទាំងអស់គ្នា ។

*I am a disabled person but I live in great honor. I have got a loan from an organization for raising chicken. I am also a motor taxi driver. I have my own house and live with my family without any discrimination. I would like to tell about my true life to all of you.*

ខ្ញុំមានស្រុកកំណើតកើតជានៅក្នុងខេត្តកំពង់ចាម ។ កាលពីនៅកុមារភាព ឳពុកម្តាយខ្ញុំធ្វើស្រែចម្ការនៅឯខេត្តកំពង់ចាម បានទទួលផលតិចតួចពេក ពួកគាត់ក៏ផ្លាស់ទីលំនៅ មករកស៊ីឯខេត្តបាត់ដំបងវិញ ។ គាត់មកទិញផ្ទះតូចមួយនៅឃុំព្រែកព្រះស្តេច ខេត្តបាត់ដំបង ។ ពេលនោះឪពុកខ្ញុំ មិនដឹងរកស៊ីអ្វី ក៏ប្រឹងជួលរ៉ឺម៉កគេយកមកធាក់ដឹកអ្នកដំណើរនៅក្នុងទីក្រុង ហើយអ្នកម្តាយខ្ញុំ ក៏ធ្វើនំអន្សមឱ្យប្អូនស្រីខ្ញុំដើរលក់ជារៀងរាល់ថ្ងៃ ។ ទោះបីរស់ក្នុងភាពលំបាកយ៉ាងណាក៏ដោយ ក៏ម្តាយឪពុកខ្ញុំឱ្យកូនៗទាំងពីរនាក់ចូលរៀននឹងគេដែរ ព្រោះគាត់ថាមានតែចំណេះវិជ្ជាទេដែលធ្វើឱ្យមនុស្សថ្លៃថ្នូរបាន ។ ពេលវេលាចេះតែវិលទៅមុខជានិច្ច នៅពេលដែលខ្ញុំមានអាយុ ១៤ឆ្នាំ ស្រាប់តែខ្ញុំមានលេចចេញស្នាមសមួយ ទំហំប៉ុនបាតដៃ ក្តិចមិនឈឺ ខ្ញុំចាប់មានការសង្ស័យ ក៏សួរឪពុកខ្ញុំដោយស្ងាត់ៗតែពីរនាក់ ។ ឪពុកខ្ញុំគាត់ពិនិត្យហើយពិនិត្យទៀត គាត់ក៏រកនឹកមួយសន្ទុះធំ ទើបប្រាប់មកខ្ញុំវិញថា៖ "ឯងប្រហែលជាកើតជំងឺឃ្លង់ហើយ!" ខណៈនោះ ខ្ញុំមានភាពតក់ស្លុតយ៉ាងខ្លាំង ខ្ញុំដើរចេញពីឪពុកខ្ញុំ ដោយក្តីបារម្ភជាទីបំផុត ។

I was born in Kampong Cham province. When I was a child, my parents were plantation farmers in Kampong Cham. Their income was not sufficient so they moved to live in Battambang. They bought a small shelter in Prek Preah Sdach commune, Battambang province. In order to support family, my father rented a bicycle with a cart to work in the town and my mother made Khmer cake called "Num AnSorm" for my younger sister to sell. Even we lived in poor condition but my parents always encouraged us to study. They thought only knowledge provided dignity to human beings. Time passed quickly, when I was 14 years old, one white skin patch is about a palm size appeared on my body. It didn't give me a pain when I scratched on that spot. I was concerned about this so I secretly discussed with my father. My father inspected that skin sign again and again and then he told me that, "You might have leprosy." I was horrible when I heard this so I walked away from my father with fear.

ក្នុងពេលនោះ ប្រហែលជាក្នុងសម័យសង្គមរាស្ត្រនិយម ខ្ញុំលួចធ្វើដំណើរទៅកាន់ភូមិត្រើង ដែលជាកន្លែងប្រមូលផ្តុំអ្នករងគ្រោះដោយសារជំងឺឃ្លង់ ។មកដល់ភូមិត្រើង ខ្ញុំបានជួបពិគ្រោះនឹងគ្រូពេទ្យ គាត់បានបើកថ្នាំឱ្យខ្ញុំ យកមកលេបនៅឯផ្ទះវិញ។ ថ្នាំនោះ ប្រហែលជាថ្នាំបេសូឡូន (Besolone) តែមួយមុខប៉ុណ្ណោះ ។ មកដល់ខេត្តបាត់ដំបងវិញ ខ្ញុំបែកគំនិតចូលហាត់រៀនក្បាច់គុនខ្មែរបូរាណ នៅក្លិបខេត្តបាត់ដំបង។ លុះមកដល់សម័យសាធារណរដ្ឋខ្មែរ ខ្ញុំបានប្រឡងឌីប្លូមធ្លាក់ ដោយយល់ឃើញឪពុកមានវ័យចំណាស់ខ្ញុំក៏សម្រេចចិត្តឈប់រៀន និងចាប់ផ្តើមធ្វើជាជាងបាញ់ថ្នាំឡាន ម៉ូតូ និងឆ្លៀតពេលទំនេរ បង្ហាត់ប្រដាល់បន្ថែមទៀត។ ខ្ញុំសូមបញ្ជាក់ថាពេលនោះ ដៃជើងខ្ញុំមិនទាន់មានភាពពិការនៅឡើយទេ។ ខ្ញុំមានសេចក្តីព្យាយាមតស៊ូប្តូរផ្តាច់ ចិញ្ចឹមឪពុកម្តាយ និងប្អូនស្រីរស់យ៉ាងស្រួលដូចគេដូចឯងដែរ។ លុះមកដល់របបប៉ុលពត គេនិរទេសខ្ញុំនិងក្រុមគ្រួសារ ឱ្យមកធ្វើស្រែនៅក្នុងឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង។ ការរស់នៅទីនោះបានជាងមួយឆ្នាំ ឪពុកម្តាយនិងប្អូនស្រីក៏ស្លាប់ជាបន្តបន្ទាប់ ។

It was the era of Sangkum Reas Niyum. I went to Troeung village without inform my parents where all leprosy affected people were assembled to live. In Troeung village, I consulted with a health professional staff, and he gave me some medicines to take at home. I remembered that they were only "Besolone Medicines". When I arrived in Battambang province, I had trained to be Khmer traditional boxer. During the era of the Khmer Republic, I failed the Junior high school exam so I had decided to give up my studying and started to be a car and motorbike spray painter. Moreover I had taught Khmer traditional boxing. At that time, my hands and legs were in good condition. I tried with my best to earn the money for my family. During Pol Pot Regime, my family and I were ostracized to work as rice farmers at Anlong Vel commune, Sanke district, Battambang province. I lived there for about one year, my father and my sister had passed away.

ខណៈនោះហើយ ដែលរោគាររបស់ខ្ញុំចាប់ចេញស្លាកស្នាមជាច្រើន និងមានការឈឺចាប់ម្តងម្កាលដែរ ដែលធ្វើឱ្យខ្ញុំមានការតក់ស្លុត និងបារម្ភជាខ្លាំងពីវាសនាអនាគត។ នៅឆ្នាំ១៩៨០ ម្រាមដៃខ្ញុំចាប់ផ្តើមក្រញ៉ង់បន្តិចម្តងៗ ជាលំដាប់។ ខ្ញុំបានចាកចេញពីខេត្តបាត់ដំបង មករស់នៅឯខេត្តកំពង់ឆ្នាំង ខ្ញុំបានជួបនឹងស្រីមេម៉ាយកូនពីរ ក៏បានរៀបការជាមួយគ្នារវាងឆ្នាំ១៩៨២។ ក្រោយពេលរៀបការរួច យើងទាំងពីរនាក់បានខិតខំរកស៊ីចិញ្ចឹមកូន និងបានបញ្ជូនកូនៗ ឱ្យចូលរៀនសាលាថែមទៀត។ មានមនុស្សជាច្រើនសួរខ្ញុំថា : ហេតុអីបានជាខ្ញុំស្រឡាញ់ប្រពន្ធ ដែលជាស្រីមេម៉ាយកូនពីរ ហើយមានអាយុច្រើនជាងខ្ញុំយ៉ាងនេះ? ខ្ញុំមិនដែលចាប់អារម្មណ៍ទៅនឹងពាក្យសំដីរបស់ពួកគេទេ ព្រោះខ្ញុំរស់នៅមានសុភមង្គលណាស់ ផ្ទុយទៅវិញខ្ញុំព្រួយបារម្ភខ្លួនឯងយ៉ាងខ្លាំង ព្រោះម្រាមដៃកាន់តែក្រញ៉ង់ រីឯបាតជើងក៏ចាប់ផ្តើមស្ពឹកតិចៗ ហើយមិនដឹងថា នឹងទៅព្យាបាលនៅទីណាផង ខ្ញុំខ្លាចចិត្តប្រពន្ធខ្ញុំទៅវិញទេ ព្រោះគាត់ពុំមានចិត្តរើសអើងដល់រូបខ្ញុំឡើយ។

At that time, the skin patches appeared on my body. Sometime I feel hurt and worried about my future life. In 1980, my fingers gradually clawed. I left from Battambang province to live in Kampong Chhnaing province where I met a widow with two children. I decide to get married her in 1982. After we got married, we worked hard and sent our children to school. Many people always asked me, why did I get married with lady who was older than me? I never concerned what they said because my family life is very good. In contrast, I concenced about my fingers because they started to claw and my feet also loss sensation. I didn't know where I could get proper treatment and cure. I was also worried about my wife's feeling because she didn't discriminate against me.

ក្នុងឆ្នាំ១៩៨៧ ខ្ញុំមានសំណាងណាស់ ព្រោះខេត្តកំពង់ឆ្នាំងចាប់ផ្តើមសេវាព្យាបាលដោយថ្នាំច្រើនមុខ (MDT) ។ ខ្ញុំគ្រាន់តែឮព័ត៌មាននេះភ្លាម ទោះបីដៃជើងខ្ញុំពិការជ្រុលក៏ដោយ ក៏ខ្ញុំមានសេចក្តីត្រេកអរណាស់។ ខ្ញុំបានចូលខ្លួនទៅព្យាបាលនៅកន្លែងលោកគ្រូពេទ្យភូរ៉ា ខ្ញុំបានលេបថ្នាំរហូតដល់២ឆ្នាំទើបឈប់។ ខ្ញុំដឹងថាខ្លួនឯងជាសះស្បើយ ហើយព្រមទាំងកូនចៅដែលរស់នៅជាមួយទាំងប៉ុន្មាន គ្មាននរណាម្នាក់ឆ្លងពីខ្ញុំឡើយ។ ខ្ញុំបានទទួលប្រាក់កម្ចីមួយចំនួន ពីអង្គការស៊ីអូម៉ាល់ (CIOMAL) សំរាប់ទិញមាន់មកចិញ្ចឹម ។ ក្រៅពីការចិញ្ចឹមសត្វ ខ្ញុំអាចរត់ម៉ូតូឌុបបន្ថែមទៀតដើម្បីជួយដោះស្រាយជីវភាពក្នុងគ្រួសារ។ សព្វថ្ងៃខ្ញុំរស់នៅជាមួយកូន មានផ្ទះប្រក់ក្បឿង ភរិយាធ្វើជាមេផ្ទះ រស់នៅប្រកបដោយសុភមង្គល និងគ្មានការរើសអើង ។

In 1987, it was lucky because Kampong Chhnaing just had Multi Drug Therapy (MDT) for curing leprosy disease. I heard this news; I was very happy even I already became a disabled person. I immediately went to see Mr. Phoura who was a provincial leprosy supervisor, and he asked me to take medicine for almost two years. I knew my disease get better because my family members were not infected by leprosy. I got some loan from CIOMAL Organization for feeding chicken. Beside this, I can earn other money from to be a motor taxi driver. Nowadays I have a house and live with my family without discrimination.



ការធ្វើរោគវិនិច្ឆ័យនិងព្យាបាលជំងឺឃ្លង់បានមកដល់យឺតពេលខ្លាំងណាស់ ដូច្នេះធ្វើឱ្យខ្ញុំក្លាយជាជនពិការ ។ ប៉ុន្តែឥឡូវនេះខ្ញុំមានការរីករាយពីព្រោះខ្ញុំព្យាបាលជាសះស្បើយមួយរយភាគរយដោយថ្នាំច្រើនមុខ ។ ខ្ញុំធ្វើការដល់ឆ្នាំ២០០៥ ហើយបានផ្ទេរមុខរបរឱ្យកូនខ្ញុំបន្ត ។ ខ្ញុំមានកូន៤នាក់ ស្រី៣នាក់និងប្រុសម្នាក់ បច្ចុប្បន្នខ្ញុំមានចៅសរុប១៥នាក់ ។ ខ្ញុំរីករាយចំពោះការចូលនិវត្តន៍ ។

***Diagnosis and treatment of leprosy came too late so I became a disabled person. But I am happy now because I am cured 100% by MDT. I worked until 2005 and handed over my business to my son to continue. I have four children, three girls and one boy. Recently, I have altogether fifteen grand children. I am happily retired.***

ខ្ញុំជាកូនកសិករធ្វើស្រែចម្ការច្បារដំណាំ កាលពីសម័យនោះ ពេលមានអាយុគ្រប់ចូលរៀន គឺចូលសិក្សានៅវត្តអន្លង់វិល ធ្វើជាសិស្សព្រះចៅអធិការវត្ត ព្រះតេជគុណ អ៊ឹប ។ លុះរៀនអក្សរសាស្ត្របានចេះដឹងគួរសម ខ្ញុំក៏សុំការអនុញ្ញាត ពីមាតាបិតារៀនផ្នែកជួសជុលម៉ាស៊ីនភ្លើង ម៉ាស៊ីនបូមទឹក និងជួសជុលវិទ្យុ នៅឯក្រុងបាត់ដំបង អស់រយៈពេលប្រហែលមួយឆ្នាំ ទើបចេញមករកស៊ីនៅផ្សារអន្លង់វិល ។ ការរកស៊ីរបស់ខ្ញុំ ក៏ចេះតែរីកដុះដាលទៅមុខជានិច្ច ហើយពេលនោះខ្ញុំមាននារីក្រមុំជាច្រើនស្រឡាញ់ចូលចិត្ត ។ ឪពុកម្តាយខ្ញុំ គាត់ឃើញខ្ញុំមានមុខរបរអាចចិញ្ចឹមជីវិតដោយខ្លួនឯងបាន ។ គាត់ក៏សម្លឹងឃើញកូនស្រីគេម្នាក់នៅឯភូមិស្វាយកង់ នាងឈ្មោះ *ពៅ ធារី* ដែលពូកែលក់ដូរនៅផ្សារស្វាយធំ ខ្ញុំបានឃើញរូបរាងគេភ្លាម ក៏ចាប់ចិត្តស្រឡាញ់ ហើយទទូចអង្វរឪពុកម្តាយឱ្យចូលស្តីដណ្តឹងតាមច្បាប់ប្រពៃណី ។ ខ្ញុំបានរៀបអាពាហ៍ពិពាហ៍ នៅឆ្នាំ១៩៦៧ ហើយមានកូន៤នាក់ ស្រី៣នាក់ និងប្រុស១នាក់ រហូតដល់សព្វថ្ងៃខ្ញុំមានរហូតដល់ចៅ១៥នាក់ហើយ ។

I was a child of a plantation farmer. In those days of my generation, most parents sent their children to study at Wat (Pagoda), I studied at Anlong Veal pagoda as a student of monk Ep, the head of a Buddhist monastery. After I finished my study as a Khmer literature; my parents allowed me to learn vocational skills as an electronic technician for one year at Battambang province. I created a repair shop at Anlong Veal market. My business was progressing well. I was an attractive boy in the village. My parents thought that I had my own job so they found a girl in Svay Kong Village to marry me. Her name was *Pao Theary*, and she also was a good salewoman at Svay Thom market. When I saw her, I immediately fell in love with her. I asked my parents to engage her and get married her in 1967. At present, I have four children: three daughters, one boy with fifteen grand children.

ខ្ញុំមានស្នាមចម្លែកមួយពណ៌ស ប៉ុនមេជើងនៅក្រោមផ្ចិតផ្នែកខាងស្តាំ។ ដំបូងខ្ញុំមិននឹកស្មានថាខ្ញុំកើតឃ្លង់ទេ ខ្ញុំរកគ្រូឱសថបូរាណដើម្បីព្យាបាល តែវាគ្មានប្រសិទ្ធភាពទាល់តែសោះ ខ្ញុំក៏មិនព្រួយបារម្ភអ្វីដែរ ព្រោះស្នាមនោះវាគ្មានផលរំខានដល់ខ្ញុំទេ។ ខ្ញុំចេះតែបន្តមុខរបរ ជាជាងជួសជុលម៉ាស៊ីនភ្លើងចាស់ៗសល់ពីសង្គម និងជួសជុលវិទ្យុម៉ាញ៉េជាប្រក្រតីតទៅទៀត។ ក្នុងពេលបន្តទៅទៀតនោះ ខ្ញុំក៏លេចចេញស្នាកស្នាមជាច្រើន ខ្ញុំចាំបានថា ស្នាកស្នាមទាំងនោះ លេចចេញប្រហែលជាក្នុងឆ្នាំ១៩៨៥ ខ្ញុំក៏ធាក់កង់ទៅមណ្ឌលសុខភាពអន្លង់វិល តែបុគ្គលិកសុខាភិបាលនៅទីនោះពុំទាន់មានជំនាញនៅឡើយ ពួកគេក៏ពុំអាចធ្វើរោគវិនិច្ឆ័យលើជំងឺខ្ញុំបានឡើយ។ ខ្ញុំត្រឡប់មកផ្ទះវិញ ក៏ខិតខំរកឱសថបូរាណមកដាំទឹកផឹក ព្រោះខ្ញុំយល់ច្រឡំស្មានតែរោគស្វាយបែក។ ខ្ញុំផឹកថ្នាំបូរាណនោះអស់បីឆ្នាំង តែស្នាកស្នាមគ្មានរលេប់បន្តិចទាល់តែសោះ តើរឹតតែចេញជាបន្តបន្ទាប់ពេញរាងកាយខ្ញុំតែម្តង។

លុះដល់ឆ្នាំ១៩៨៨ ខ្ញុំមានបញ្ហាយ៉ាងធ្ងន់ធ្ងរ ជាមួយនឹងអវៈយវៈរបស់ខ្ញុំចាប់ផ្តើមស្ពឹកដូចជាពាក់ស្រោមដៃស្រោមជើង ។

There was one skin sign about the size of a big toe on the lower part of my abdomen. At first, I didn't know that I had leprosy. I found a Khmer traditional doctor to cure but it did not disappear. I didn't care about this spot because it didn't make me hurt, and I did my job as normal. In 1985, I remembered that the new skin symptom appeared all over my body, so I rode my bicycle to the health center. The staff over there didn't have the skill to diagnose leprosy yet so I came back home and continued to cure with Khmer traditional medicine. At first, I suspected that it was syphilis so I drank about three pots of Khmer traditional medicine but my skin patches did not disappear, and the other new skin patches appeared more and more all over my body.

In 1988, I had a serious problem with hands and feet became numb, and I felt as I was wearing socks and gloves.

ថ្ងៃមួយពេលជួសជុលម៉ាស៊ីនវាយជីឥដ្ឋ ខ្ញុំដើរជាន់ដែកស្រួចមួយមុតមិនឈឺផង ហើយដំបៅនោះព្យាបាលពុំជាសោះ។ យប់មួយខ្ញុំរសាប់រសល់ខ្វល់ក្នុងចិត្តជាខ្លាំង ខ្ញុំដេកស្តាប់វិទ្យុខេត្តបាត់ដំបង ពេលនោះគេបានផ្សព្វផ្សាយអប់រំសុខភាពពីជំងឺហង់សិន គេថា ខេត្តបាត់ដំបងមានបើកព្យាបាលផ្នែកជំងឺហង់សិននិងជំងឺដំបៅងារ គឺបើកព្យាបាលនៅពេទ្យឃាយជី។ ពាក្យថាជំងឺហង់សិនគឺជាពាក្យថ្មី ខ្ញុំឆ្ងល់តើហង់សិនជាអ្វីទៅ? ខ្ញុំសួរ *ជាង គ្រី* ជាមិត្តភក្តិ ជាជាងចម្លាក់ផង និងប្រកបមុខរបរជាអ្នកសាកអាគុយគាត់នឹកមួយសន្ទុះ ទើបប្រាប់ខ្ញុំថា វាជាជំងឺឃ្លង់ ខ្ញុំកើតឃ្លង់ហើយ តែគេថាឃ្លង់គឺជាជំងឺស្នូរពូជ ខ្ញុំរកនឹកយ៉ាងយូរថាពូជខ្ញុំគ្មាននរណាម្នាក់កើតឃ្លង់ទេ។ រាត្រីនោះខ្ញុំសំងំគេងពិចារណាពេញមួយយប់ ទើបយល់ច្បាស់ថាជំងឺនេះជាជំងឺឆ្លង ព្រោះពីនៅលីវខ្ញុំដើរខិលខូចគ្រប់ទីកន្លែងបានជាលទ្ធផលផ្តល់ឱ្យខ្ញុំបែបនេះ។ ស្អែកឡើង ខ្ញុំធ្វើដំណើរទៅកាន់ពេទ្យឃាយជី រួចចូលខ្លួនទៅពិនិត្យព្យាបាល នៅផ្នែកអាគារប្រយុទ្ធប្រឆាំងនឹងជំងឺហង់សិន។

One day, while I was repairing a machine, I stepped on a sharp metal it didn't hurt and this wound never healed. I was worried and could not sleep well. One night, when I was listening to Battambang radio broadcast, they were announcing about leprosy disease. They said,"Now Battambang province had been provided to cure leprosy, Hansen, and yaws (infectious tropical disease) in Nun Hospital." Hansen was a new word; I wondered what does it mean? I asked my friend named ***Kry*** who was a former sculptor but working as a battery charger. He replied me that "Hansen" was "Klung" (Khmer word used for Leprosy). I thought I had leprosy, and I heard elderly people say leprosy was hereditary but none of my ancestors had leprosy. I was puzzled. I thought that it could also be a transmitted disease because when I was single I had gone everywhere and had a rather liberal life with many girls. The next day, I went to Nun hospital and consulted the leprosy section.

ខ្ញុំស្គាល់លោកគ្រូពេទ្យ *ឡេង*ច្បាស់ណាស់ ព្រោះជាអ្នកភូមិអន្លង់វិលដូចគ្នាគាត់បានហៅសហការីជាអ្នកកាន់ផ្នែកមន្ទីរពិសោធន៍ មកធ្វើវិភាគលើរូបខ្ញុំ ដោយយកទឹករងៃនៅទងត្រចៀក ទឹកច្រមុះ និងនៅលើតែមនៃស្នាមនៅដើមដៃ។ មួយថ្ងៃក្រោយមក លោកគ្រូឡេង បានយកថ្នាំមកឱ្យខ្ញុំលេប និងជាបន្ទាប់មកជារៀងរាល់ខែ គឺខ្ញុំលេបថ្នាំនោះ អស់រយៈពេលពីរឆ្នាំគត់។ ខ្ញុំព្យាបាលដោយថ្នាំច្រើនមុខ MDT ចប់សព្វគ្រប់ តែបាតជើងខ្ញុំនៅតែដំបៅដដែល។ ក្នុងឱកាសនោះ លោកគ្រូឡេង បានចៀរដំបៅបាតជើងខ្ញុំ ហើយគាត់រុំឱ្យចំនួនបីថ្ងៃ គាត់ពន្យល់ណែនាំខ្ញុំពីរបៀបព្យាបាលជាពិសេស គាត់ឱ្យខ្ញុំ យកម្រាមដៃម្រាមជើងត្រាំទឹក ហើយហាត់ពត់ជារៀងរាល់ថ្ងៃ។ ខ្ញុំធ្វើតាមការណែនាំរបស់គាត់រាល់ថ្ងៃ ប្រហែលជាបីខែ ម្រាមដៃខ្ញុំក៏ត្រង់ធម្មតា ហើយដំបៅបាតជើងក៏ជាដោយមិនដឹងខ្លួន ។ ខ្ញុំប្រកបមុខរបរជាប្រចាំ រហូតដល់ឆ្នាំ២០០៥ ទើបឈប់សម្រាក ហើយប្រគល់ទៅឱ្យកូនប្រុសខ្ញុំជំនួសវិញ។

I knew Doctor *Leng*, the provincial leprosy supervisor, very well, because he lived in the same village in Anlong Veal. He asked his staff to take some specimen from my ear lobe, my nose and from the patches on my skin send them to the laboratory. The next day, Doctor Leng brought medicine to my house. It was Multi Drug Therapy. He brought it to me every month for two years, and I finished my treatment but the ulcer on my foot did not heal. Doctor Leng scraped the hard skin and did dressing for me. He explained to me about soaking and scraping with hands and feet exercise. I followed his advice for almost three months, and my fingers became normal and my ulcer healed. I worked until 2005 and handed over my business to my son to continue.




ខ្ញុំត្រូវផ្តែផ្តាំចំពោះជនគ្រប់រូបថា បើនរណាម្នាក់មានសញ្ញាសង្ស័យជំងឺឃ្លង់ អ្នកនោះ ត្រូវប្រញាប់ទៅមណ្ឌលសេវាជំងឺឃ្លង់ វាការពារអ្នកពីភាពពិការ ។

I would recommend to all people who suspected have leprosy. Please hurry up go to leprosy services; it will protect you from disability.

ខ្ញុំមានកំណើតកើតជានៅស្រុកសង្កែ ខេត្តបាត់ដំបង។ ក្រុមគ្រួសារខ្ញុំកាលពីសង្គមចាស់ គឺជាអ្នកមានដាច់គេនៅផ្សារកំពង់ព្រះ នេះតែម្តង ។ ផ្ទះខ្ញុំនៅក្បែរផ្ទះ ***លោក នូ ហាច*** អ្នកនិពន្ធរឿងផ្កាស្រពោន និងអតីតអ្នកចម្រៀង អ៊ឹម សុងស៊ឺម។ ខ្ញុំបានចូលនិវត្តពីការងារហើយ និងរស់នៅឯផ្ទះ។ ឥឡូវនេះ ខ្ញុំសូមរំលឹកជីវិតពិតនៃខ្ញុំ និងចែករំលែកដល់អ្នកទាំងឡាយ ។

ខ្ញុំបានកើតក្នុងឆ្នាំ១៩៣៣ និងរស់នៅឆ្លងកាត់ជាច្រើនជំនាន់ ។ ខ្ញុំបានទទួលជោគជ័យ ក្នុងមុខរបររបស់ខ្ញុំ និងមានកូនប្រាំនាក់ ប្រុសពីរ ស្រីបី និងចៅដប់ប្រាំនាក់។ កូនខ្ញុំមានមុខរបរ និងផ្ទះផ្ទាល់ខ្លួន កូនខ្ញុំម្នាក់ជាវេជ្ជបណ្ឌិត និងជាធម្មតាពាត់មានការយល់ដឹងអំពីឃ្លង់។ ខ្ញុំក៏ស្គាល់ជំងឺឃ្លង់ច្បាស់ ដោយសារខ្ញុំជាអ្នករងគ្រោះដោយសារជំងឺនេះ និងមានភាពពិការ។ ខ្ញុំបានព្យាយាមធ្វើការព្យាបាល ដោយចលនាយ៉ាងប្រុងប្រយ័ត្ន រហូតដល់ខ្ញុំបានជាធម្មតាវិញ។

ក្នុងឆ្នាំ១៩៥៥ ខ្ញុំបានរៀបការជាមួយនាង *អេង ហុង* ដែលរស់នៅភូមិជាមួយគ្នា (ផ្សារកំពង់ព្រះ) ។

I was born in Sangke district, Battambang province. My family was a former rich-family in Kampong Preah market during *Sangkum Reas Niyum* era. My house was located near Mr. *Nou Hach*'s house, a former well-known novelist and the author of a novel entitled "Phka Srapoun (Faded Flower)", and also lived nearby the famous singer, *Em Song Seum*. I have already retired from my job, and now I stay at home. Now I would review my life and share it with you.

I was born in 1933 and have lived through many generations. I was successful in my business and have five children, two sons, three daughters and fifteen grand-children. My children have jobs and have their own house. One of my sons is a medical doctor with full knowledge of leprosy disease. I also know leprosy well as I am a person affected by leprosy and disabled person. I did physical therapy thoroughly until I became normal.

In 1955, I married Miss *Eng Hong* who lived in the same village, Kampong Preah Market.

ព្រះរាជាណាចក្រកម្ពុជា បានទទួលឯករាជ្យពេញបរិបូរណ៍ពីបារាំង នៅឆ្នាំ១៩៥៣។ នៅពេលនោះ ខ្ញុំទិញស្រូវពីអ្នកភូមិជិតខាង និងលក់ឱ្យពាណិជ្ជករវៀតណាម ជារៀងរាល់ឆ្នាំ។ មុខរបររបស់ខ្ញុំ ដំណើរការបានល្អ ហើយខ្ញុំបានចំណេញជាច្រើន ខ្ញុំទិញត្រាក់ទ័រមួយគ្រឿង និងដីស្រែ៥ហិកតា។ វាជាភ័ព្វសំណាងរបស់ក្រុមគ្រួសារខ្ញុំណាស់ ព្រោះឆ្លងផុត ពីរបបវាលពិឃាតទាំងកូនទាំងប្រពន្ធ។ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ ខ្ញុំបានរស់នៅមុខវត្តបញ្ញា ព្រោះខ្ញុំយល់ឃើញថា ជាទីកន្លែងមាន សុវត្ថិភាពល្អ ដោយមកពីកងទ័ពវៀតណាម យកវត្តនេះធ្វើជាបន្ទាយមួយយ៉ាងធំ មានទាហានរាប់រយនាក់ និងមានកាំភ្លើងធំៗ ទៀតផង។ ក្នុងរយៈពេលនោះ មានការខ្វះខាតខ្លាំងណាស់ ខ្ញុំក៏ចាប់ផ្តើមរាប់ញាតិផៅ ដែលជាអ្នកភូមិផងរបងជាមួយ បបួលគ្នាទៅនេសាទត្រីនៅតំបន់ព្រៃរនាម។ ពេលនោះ ក៏មានក្រុមគ្រួសារអ្នកកើតជំងឺឃ្លង់ពីរបីគ្រួសារដែរ តែក្នុងពេលនោះ ខ្ញុំក៏ពុំបានជាចាប់អារម្មណ៍ ពីការឆ្លងជំងឺនេះប៉ុន្មានទេ ព្រោះសម័យនោះ ម្នាក់ៗព្រួយតែពីរឿងជីវភាពតែប៉ុណ្ណោះ ។

Cambodia has obtained full independence from France in 1953. At that time, I bought rice from local villagers and sold to Vietnamese businessman for every year. My business ran very well and I was making much profit. I bought one tractor and five hectares of rice field. It was my fortune that my family, wife and children, survived from the killing fields of Pol Pot regime. After, the government liberated the nation from Pot Pot on 7$^{th}$ January, 1979, I lived in front of Pannha Pagoda; I thought it was the safe place because hundreds of Vietnamese soldiers occupied that pagoda as military barracks with many weapons and armed vehicles. During that time, there was shortage of everything. I became acquainted with the villagers who lived nearby and went along with them to go fishing in the flooded forests. A few of these family members had leprosy but I wasn't worried much about transmission as we were only concerned about our living.

លុះមកដល់ឆ្នាំ១៩៨៥ ស្រាប់តែមានស្នាកស្នាមមួយ ទំហំប៉ុនបាតដៃហើយស្ពឹក ខ្ញុំក៏ចាប់អារម្មណ៍ថា ខ្ញុំបានឆ្លងជំងឺឃ្លង់ហើយ។ ខណៈនោះខ្ញុំពិបាកចិត្តជាខ្លាំង ព្រោះអ្នកជំងឺឃ្លង់ដែលខ្ញុំធ្លាប់ចេញចូល គាត់មានភាពពិការគួរឱ្យភ័យខ្លាច។ ខ្ញុំមិននៅស្ងៀមទេ ខ្ញុំព្យាយាមស៊ើបសួរដំណឹងគេនៅត្រើង ដែលធ្លាប់ជាកន្លែងព្យាបាលឃ្លង់ពីមុន តែគេនិយាយថា តំបន់នោះមិនទាន់បង្កើតឡើងវិញទេ ខ្ញុំរសាប់រសល់ខ្វល់ក្នុងចិត្តជាខ្លាំង ធ្វើការអ្វីក៏មិនពេញដៃពេញជើងទេ។ ឆ្នាំ១៩៨៨ រាងកាយខ្ញុំមានស្នាកស្នាមពេញខ្លួនទៅហើយ ពេលនោះបាតដៃបាតជើងខ្ញុំមានភាពស្ពឹកអស់ទៅហើយ តែជាសំណាងខ្ញុំដែរ ព្រោះពេទ្យឃាយជីមានបើកសេវាព្យាបាលជំងឺនោះ។ ថ្ងៃមួយឱកាសល្អ មានគ្រូពេទ្យម្នាក់ ឈ្មោះ *ខ្វាន់ ប្រាច* បាននាំខ្ញុំទៅពិនិត្យនៅផ្ទះលោកគ្រូពេទ្យ *ឡេង* នៅភូមិអន្លង់វិល។ លោកគ្រូពេទ្យ ឡេង ពិនិត្យតែមួយគ្រូស ក៏ណាត់ខ្ញុំឱ្យទៅជួបគាត់ នៅមន្ទីរពេទ្យឃាយជីដើម្បីធ្វើសំណុំលិខិតព្យាបាលដោយប្រើថ្នាំច្រើនមុខMDT សម្រាប់រយៈពេល២ឆ្នាំ។ ក្នុងពេលព្យាបាលនោះ សម្បុរស្បែកខ្ញុំពិបាកយកភ្នែកមើលណាស់ តែខ្ញុំនៅតែព្យាយាម ធ្វើតាមការណែនាំរបស់គ្រូពេទ្យជំនាញ មិនឱ្យខ្ចោះឡើយ ហើយស្បែករបស់ខ្ញុំ វាប្រែជាធម្មតាវិញ ក្រោយពេលបញ្ចប់ការព្យាបាល។

In 1985, I had one insensitive skin patch about a palm size. I thought it was leprosy and was worried about this. People who had leprosy that I had met had ugly appearances so I could not dismiss my fear. I tried to find information about Troeung village where was the former leprosarium but it was not reopened yet. I was very worried and anxious until I could not work well. In 1988, my body was full of skin lesions; my hands and feet were numb. Fortunately, Nun Hospital had service to cure this disease. One bright day, Mr. *Kvan Prach*, a health staff, brought me to Mr. *Leng*'s house at Anlong Veal. Mr. Leng examined me for a while and instructed me to see him at Nun Hospital to prepare documents for my treatment with Multi Drug Therapy (MDT) for 2 years. I followed the guidance of professional health staff. During MDT treatment, my skin color did not look good but it returned normal after the treatment was over.

នៅឆ្នាំ១៩៩០ ខ្ញុំលេបថ្នាំគ្រប់ចំនួនបានជាសះស្បើយមួយរយភាគរយ តែភាពពិការនៅតែដដែល ។ ខ្ញុំបានទៅជួបលោកគ្រូពេទ្យឡេងទៀត គាត់បានណែនាំខ្ញុំឱ្យធ្វើលំហាត់ប្រាណ បិទបើកភ្នែករាល់ថ្ងៃ ព្រោះពេលនោះភ្នែកខ្ញុំឡើងក្រហម ហើយមានការលំបាកក្នុងការបិទបើក។ មិនតែប៉ុណ្ណោះសោត ខ្ញុំមានដំបៅបាតជើងថែមទៀត ទោះបីខ្ញុំមានជំងឺព្យាបាលរយៈពេល២ឆ្នាំក៏ដោយ ក៏ជីវភាពគ្រួសារនៅតែមានស្ថានភាពល្អប្រសើរជានិច្ច។ ក្រោយមកប្រហែលក្នុងឆ្នាំ១៩៩១ ខ្ញុំឱ្យកូនប្រុសពៅខ្ញុំប្រឡង នៅសាលាក្របាមជាប់ជានិស្សិតវេជ្ជសាស្ត្រ។ សព្វថ្ងៃគាត់ធ្វើការនៅមន្ទីរពេទ្យមង្គលបូរី ខេត្តបន្ទាយមានជ័យ ពីដើមជាស្រុកមួយនៃខេត្តបាត់ដំបង ។

ខ្ញុំសូមផ្តាំដល់ប្រជាពលរដ្ឋទាំងអស់ បើមានស្នាកស្នាមលើស្បែកគួរឱ្យសង្ស័យ សូមប្រញាប់ទៅកាន់ ផ្នែកប្រយុទ្ធនឹងជំងឺហង់សិន លោកអ្នកនឹងអាចជៀសផុតពីភាពពិការដោយសារជំងឺឃ្លង់ ។

In 1990, I completed my treatment and 100% cured with MDT, but my disability remained. I went to see Mr. Leng and he explained to me about eye exercises. My eyelid was red and difficult to close and my foot also had an ulcer. Even though, I had treatment for 2 years, my standard of living was progressing well. In 1991, my last son successfully passed the entrance exam to study as a medical doctor. Currently, he works at Mongkul Borey Hospital, Banteay Meanchey province, formerly district of Battambang Province.

I would recommend to all people that if anyone suspected skin sign of leprosy the person should please hurry to see leprosy services. It will protect you from disability.



ខ្ញុំមានជំនាញ និងមានមុខរបរមួយ ខ្ញុំរស់នៅដោយថ្លៃថ្នូរ គ្មានអ្នកណាម្នាក់រើសអើង ខ្ញុំទេ ហើយគេគួរសមជាមួយខ្ញុំ គេទាំងឡាយយល់ច្បាស់ណាស់ថា ជំងឺឃ្លង់ព្យាបាលជា មួយរយភាគរយ ។

***I have skill and have a job. I live with dignity. People do not discriminate against me and they are sympathetic to me. They clearly understand that leprosy is 100% curable.***

ខ្ញុំសូមរៀបរាប់ជូនពីខ្សែជីវិតរបស់ខ្ញុំដល់ពិភពលោក ៖ ក្នុងនាមជាមនុស្សម្នាក់ដែលកើតមកក្នុងត្រកូលអ្នកកើតឃ្លង់ គឺជាជីវិតមួយដ៏សែនឈឺចាប់បំផុត ។ ខ្ញុំមានកំណើតកើតជា និងរស់នៅតំបន់ដាច់ស្រយាលមួយនៃខេត្តសៀមរាប ខ្ញុំចាំថាបើក្រឡេកមើលជុំវិញខ្លួនខ្ញុំ គឺមានអ្នកជំងឺឃ្លង់ជាច្រើន ។ ពួកគេបានភៀសខ្លួនមករស់នៅក្បែរប្រាង្គប្រាសាទបន្ទាយស្រី ។ ពេលនោះខ្ញុំមិនទាន់កើតជំងឺឃ្លង់នៅឡើយទេ ប៉ុន្តែពេលចូលទៅរៀន មានការរើសអើងពីកូនអ្នកភូមិដទៃខ្លាំងណាស់ ។ ជួនកាលពេលខ្លះលោកគ្រូក៏មានការរើសអើងខ្លាំងណាស់ដែរ ទោះបីពិបាកក្នុងអារម្មណ៍យ៉ាងណាក៏ដោយ ក៏ខ្ញុំនៅតែព្យាយាមខាំមាត់សង្កត់ចិត្ត រៀនដល់បានប្រឡងឌីប្លូម ជាប់ជាស្ថាពរ ។ លុះដល់ឆ្នាំ ២០០៣ ឃើញនិងអ៊ុនជាក់អារក្សធ្វើ ខ្ញុំក៏បានកើតរោគឃ្លង់ ដូចឪពុកម្ដាយខ្ញុំ ពេលនោះហើយដែលខ្ញុំកំពុងបន្តការសិក្សានៅវិទ្យាល័យឯខេត្តសៀមរាប ។ ខ្ញុំក៏បានទៅជួបលោកគ្រូពេទ្យ *សុខ មេត* ដែលជាប្រធានកម្មវិធីហង់សិនប្រចាំខេត្ត ។ លោកក៏បានធ្វើប័ណ្ណគ្លីនិក និងផ្ដល់ការព្យាបាលឱ្យខ្ញុំចំនួនមួយឆ្នាំពេញ ហើយស្បែកខ្ញុំឡើងពណ៌ខ្មៅដោយសារថ្នាំ ។ មិត្តភក្តិដែលធ្លាប់ជិតដិតគ្នាពីមុន សួរគេមួយម៉ាត់ គេនិយាយរកមួយម៉ាត់ ធ្វើឱ្យខ្ញុំមានអារម្មណ៍ថា ខ្លួនរស់នៅក្នុងភពមួយឆ្ងាយសែនឆ្ងាយឯកោ ។

I would like to tell to the world about my story: To have a name of leprosy family is a bitter life. I was born and lived in the remote area of Siem Reap province. I remembered that many leprosy patients lived around me. They fled to live near Banteay Srey Temple. I did not have leprosy yet but when I went to school, I was discriminated by children from other villages. Sometimes, teachers also discriminated against me. Even though, it was very depressure on me, I managed to finish junior high school. In 2003, unfortunately I developed leprosy as my parents. It was the time when I was studying at Siem Reap High School. I went to consult with Mr. *Sameth*, provincial leprosy supervisor. He prepared documents and provided me with MDT for one year. My skin color became black due to MDT. My closed-friends talked to me less than before when they knew I have leprosy, and it made me feel lonely.

ទុក្ខជាន់លើទុក្ខកំពុងតែវិយោគសោយសោក ស្រាប់តែរោគចង្រៃមួយទៀតមកជ្រៀតជ្រែក គឺរោគប្រតិកម្ម តាមការអះអាងរបស់ពេទ្យ ។ ខណៈនោះ ខ្ញុំគ្រុនងើបលែងរួច បានមិត្តសម្លាញ់ម្នាក់ ឈ្មោះ *ផល* ជិះកង់ទៅប្រាប់លោកគ្រូពេទ្យ *សុខ មេត* ។ គាត់គ្រាន់តែដឹងភ្លាម ក៏ជិះយ៉ាម៉ាហាត្រៃពហើស មកសួរសុខទុក្ខខ្ញុំដល់ទីវត្តអារាម ដែលខ្ញុំស្នាក់នៅ ។ គាត់បានឱ្យខ្ញុំលេបថ្នាំបានមួយសប្តាហ៍ ក៏បញ្ជូនខ្ញុំតាមរថយន្ត ***លោកភាព*** មកកាន់មន្ទីរពេទ្យកៀនឃ្លាំង ។ ខ្ញុំនៅសម្រាកព្យាបាលក្នុងមន្ទីរពេទ្យកៀនឃ្លាំង គ្មានញាតិផៅបងប្អូនទេ អស់រយៈពេលប្រហែលបីខែ ។ លោកវេជ្ជបណ្ឌិត *ឃួន ងួនហេង* តែងតែចេញចូល និងបង្ហាត់បង្រៀនខ្ញុំឱ្យធ្វើលំហាត់តាមគាត់ តែទីបំផុតត្របកភ្នែកខ្ញុំក៏នៅតែបិទបើកមិនបាន លោកក៏បញ្ជូនខ្ញុំឱ្យទៅធ្វើការវះកាត់នៅក្នុងមន្ទីរពេទ្យកាល់ម៉ែត ។ នៅក្នុងឆ្នាំដដែល លោក *ប៊ូ សុផល* តំណាងអង្គការស៊ីអូម៉ាល់ លោកបានឱ្យខ្ញុំទៅរៀនជាជាងអេឡិចត្រូនិចអស់រយៈពេលប្រហែលបីខែ ទើបលោកបញ្ជូនខ្ញុំមកកាន់ខេត្តសៀមរាបវិញ ។

I suffered again and again. In addition to suffering leprosy, I also suffered reaction as be affirmed by health staff. Meanwhile, my condition turned worse and I could not get up. One of my friends named *Phal* rode a bicycle to tell Mr. *Sameth*. He came on his motorbike to the pagoda where I stayed. He gave medicine to me for one week and sent me in Mr. *Pheap*'s car to Kien Kleang Leprosy Rehabilitation Center. In the center, I didn't have any relative to rely on and I stayed here about 3 months. Dr. *Khuon Nguon Heng* explained to me about eye exercise but it did not improve so he sent me for eye reconstructive surgery at Calmette Hospital. In the same year, Mr. *Bou Sophal*, the representative of CIOMAL organization, sent me to vocational training school for three months where I was trained as an electric technician before coming back to Siem Reap.

មកដល់ខេត្តសៀមរាបខ្ញុំទៅជួបឪពុកម្តាយបងប្អូនដោយសុំលាពួកគាត់ដូរទីកន្លែងរស់នៅ ធ្វើជាជាងជួសជុលវិទ្យុ ម៉ាញ៉េ និងទូរទស្សន៍ នៅផ្សារពួកដើម្បីលាក់បាំងប្រវត្តិរូបដ៏សែនអាម៉ាស់នោះ។ លុះដល់ឆ្នាំ២០០៨ ខ្ញុំបានរៀបការជាមួយនារីម្នាក់ឈ្មោះ*ហ៊ុលវឿន* រស់នៅភូមិតាប៉ាងស្រុកពួកខេត្តសៀមរាប។ បន្ទាប់ពីបានរៀបការរួច ខ្ញុំក៏បានបើកតូបមួយប្រកបរបរជាជាងជួសជុលម៉ាញ៉េនិងទូរទស្សន៍ជារៀងរហូតមក ហើយនៅទីនោះញាតិមិត្តដែលដឹងថាខ្ញុំជាមនុស្សធ្លាប់កើតឃ្លង់ក៏ដោយក៏អ្នកស្រុកនោះគ្មានការរើសអើង ហើយផ្ទុយទៅវិញ ពួកគាត់កាន់តែអាណិតអាសូរខ្ញុំថែមទៀតព្រោះគាត់យល់ច្បាស់ណាស់ថាជំងឺឃ្លង់សព្វថ្ងៃនេះអាចព្យាបាលជា មួយរយភាគរយ ហើយដោយឥតគិតថ្លៃទៀតផង។



Arrived in Siem Reap province, I asked my parents to change the place of living to Pourk Market so I can start my business where people do not know my background. In 2008, I married Miss Hol Voeun who was in the Pourk district, Siem Reap province. After I got married, I created a shop to repair tape players and TVs. Even we live at this new place so people know that I have been released from leprosy treatment. But fortunately people do not discriminate against me and they are sympathetic to me. They clearly understand that leprosy is 100 per cent curable and for free of charge.



ខ្ញុំមានសេចក្ដីរីករាយដោយសារអ្នកមកសម្ភាសន៍ខ្ញុំ និងភរិយាខ្ញុំ ។ សព្វថ្ងៃខ្ញុំធ្វើការជាជាងជួសជុលម៉ូតូ ហើយប្រពន្ធខ្ញុំជាជាងកាត់ដេរសំលៀកបំពាក់ ។ ខ្ញុំជួយមិត្តខ្ញុំឱ្យមកទទួលការព្យាបាលទាន់ពេលវេលា ខ្ញុំគិតថា វាជាអំពើកុសលរបស់ខ្ញុំដែលបានជួយគាត់ ។

***I am so happy that you came to interview me and my wife. Currently, I work as a motorbike repairer and my wife works as a tailor. I helped my friend to get treatment on time. I thought it was my merit to help him.***

ខ្ញុំមានអាយុ២១ឆ្នាំ រស់នៅក្នុងស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ។ ពេលពីកុមារភាព ខ្ញុំរៀននៅសាលាបឋមសិក្សាសាលាវិស័យ ។ ខ្ញុំរៀននៅទីនោះ រហូតដល់បញ្ចប់ថ្នាក់អនុវិទ្យាល័យ ហើយបានលះបង់ការសិក្សាដើម្បីជួយគ្រួសារខ្ញុំក្នុងការងារធ្វើស្រែចម្ការវិញ។ នៅពេលខ្ញុំអាយុ១៩ឆ្នាំ ខ្ញុំបានចាប់ចិត្តស្រឡាញ់នារីម្នាក់ឈ្មោះ *អមរា* ដែលរស់នៅភូមិជាមួយគ្នា។ ដោយក្តីស្នេហ៍ពិត និងទៅតាមប្រពៃណីខ្មែរ ខ្ញុំបានប្រាប់គ្រួសារដើម្បីភ្ជាប់ពាក្យជាមួយនាង ហើយគ្រួសារគាត់ក៏បានយល់ព្រម ។ យើងបានរៀបការនៅខែកញ្ញា ឆ្នាំ២០០៨។ ក្រោយរៀបការរួច យើងទាំងពីរនាក់រស់នៅយ៉ាងសុខដុមរមនាជាទីបំផុត យើងទាំងពីរមានចិត្តតែមួយ ។ វាសុទ្ធសឹងតែជារឿងរបស់សត្វលោក សេចក្តីសុខលាយនឹងភាពផ្អែមល្ហែមមិនបានប៉ុន្មានផង ផ្ទៃមេឃដែលធ្លាប់តែមានពណ៌ខៀវខ្ចីក៏ត្រូវស្រមោលខ្មៅមួយផ្ទាំងមកបាំងយ៉ាងតក់ក្រហល់បំផុត ។ ខណៈនោះស្រាប់តែមានស្នាមសមួយ ផុសឡើងនៅកំភួនដៃខាងឆ្វេង ហើយពីមួយថ្ងៃទៅមួយថ្ងៃ ស្នាមនោះកាន់តែបង្ហាញភិនភាគច្បាស់ឡើងៗ និងមានភាពស្ពឹក ។ ជាចៃដន្យល្អ មិនបាច់មានការមន្ទិលសង្ស័យច្រើន ក្រុមយុទ្ធនាការរបស់កម្មវិធីជាតិប្រយុទ្ធប្រឆាំងនឹងជំងឺហង់សិន បានចុះស្រាវជ្រាវមកដល់ផ្ទះគាត់តែម្តង ។

I am 21 years old and live in Prasath Palaing district, Kampong Thom province. When I was a child, I studied at Sala Ve Sai primary school. I stopped study and help my parents to do farming when I finished junior high school. When I was 19 years old, I fell in love with a girl, *Amara*, who lived in the same village so I told my parents to get an engagement with her. On September 2008, we decided to get married with happiness in family. As human beings, we lived in harmony but the clear sky became dark very shortly. One white skin patch appeared on my left forearm. Day after day, it became clearer with insensitivity. Fortunately, a team of National Leprosy Elimination program campaign reached his home.

ពេលនោះ លោកវេជ្ជបណ្ឌិត *ធារ៉ាត់* តំណាងកម្មវិធីជាតិ បានពិភាក្សាជាមួយប្រធានផ្នែកកម្មវិធីហង់សិនខេត្តកំពង់ធំ ឱ្យគាត់បានព្យាបាលដោយថ្នាំច្រើនមុខ MDT ចាប់ពី ថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩ តែម្តង។ ក្នុងពេលយុទ្ធនាការស្រាវជ្រាវរកជំងឺឃ្លង់ ពេលនោះខ្ញុំក៏បានស្តាប់ការណែនាំពន្យល់ពីលោកគ្រូពេទ្យ ដឹងពីរោគសញ្ញានៃជំងឺឃ្លង់បានច្បាស់ ខ្ញុំក៏បានប្រាប់ឈ្មោះ ***ទូច ហ៊ីម*** ភេទប្រុស អាយុ២០ឆ្នាំ ដែលរស់នៅក្នុងភូមិជាមួយគ្នាឱ្យទៅទទួលការព្យាបាលនៅខេត្តកំពង់ធំតែម្តង។ក្នុងមួយជាតិនេះខ្ញុំគិតថា បានជួយមិត្តភ័ក្រ្តឱ្យទទួលការព្យាបាលទាន់ពេលវេលា ឆ្លងផុតពីភាពពិការធ្វើឱ្យខ្ញុំសប្បាយចិត្តណាស់ ព្រោះខ្ញុំយល់ថា ជាកុសលផលបុណ្យមួយ ដែលខ្ញុំបានជួយមនុស្សម្នាក់ឱ្យឆ្លងផុត ពីភាពពិការដោយសារជំងឺឃ្លង់។ ក្រោយពេលព្យាបាលចប់ យោងទៅលើបាតដៃបាតជើងខ្ញុំមានភាពស្ពឹក កម្មវិធីជាតិសហការជាមួយអង្គការដៃគូ បានឱ្យរូបខ្ញុំទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ជាជាងជួសជុលម៉ូតូនៅបន្ទាយព្រាប។

Dr. *Thearath*, the national leprosy supervisor responsible for Kampong Thom province, treated me with Multi Drug Therapy (MDT) from 13 January, 2009. During the campaign for leprosy new case detection, I heard the doctor explain the symptoms of leprosy and I understood it clearly. So I sent *Touch Him*, 20 years, my old friend who lived in the same village to get treatment in Kampong Thom. I was very happy that my friend ***Touch Him*** got treatment in time before any disability occurred. I was very happy that I could help him. I thought it was my merit and a strong point to help a person and protect him from leprosy disability. Although I finished my treatment for leprosy due to numbness of hand and feet I needed exercises and training. National Leprosy Elimination Program in Cooperation with partner referred me to vocational training and I was trained at Banteay Preab vocational training school as a motorbike repairer.

សព្វថ្ងៃនេះ ខ្ញុំទាំងពីរនាក់ពុំទាន់មានកូនបន្តពូជពង្សវង្សត្រកូលនៅឡើយទេ ។ ខ្ញុំបែកពីឪពុកម្តាយ ស្ថិតនៅតាមដងផ្លូវមួយកន្លែង នៃស្រុកប្រាសាទបល្ល័ង្គ ដោយធ្វើជាជាងជួសជុលម៉ូតូ មានអតិថិជនមកធ្វើជាហូរហែ ដោយគ្មានការរើសអើងពីនរណាម្នាក់ឡើយ ។ កត្តាមិនរើសអើងនេះ ខ្ញុំយល់ថាគឺជាការប្រឹងប្រែងអប់រំសុខភាពពីក្រសួងសុខាភិបាល ក៏ដូចជាកម្មវិធីគ្រប់ជាន់ថ្នាក់ លះបង់កម្លាំងកាយចិត្ត ទម្លុះភាពរើសអើងជាច្រើនទសវត្សមកហើយ បានប្រកបដោយជោគជ័យល្អណាស់ ។




At this moment, we do not have children yet. We lived separately from my parents along the way to Prasath Palaing district. My clients came to my workshop but they did not have any discrimination against me. The reason that I did not suffer any discrimination due to leprosy is the result of hard work of health education program by the ministry of health and all levels of staff devoted their strength and hearts to eliminate discrimination successfully which they have work for over many decades and I am very grateful for that.

ចំណែកឧត្តមភរិយារបស់ខ្ញុំវិញ នាងមិនទំនេរទេ តាំងពីព្រលឹមរហូតព្រលប់ នាងដេរជាប់តែម្តង គឺសម្រាកតែពេលបាយតែប៉ុណ្ណោះ។ ជីវភាពរស់នៅក្នុងគ្រួសារខ្ញុំ ចេះតែមានភាពប្រសើរឡើងជានិច្ច តែពេលខ្លះអារម្មណ៍ខ្ញុំ នៅតែឆ្ងល់នៅតែមានភាពអាថិកំបាំង តើខ្ញុំឆ្លងរោគឃ្លង់នេះពីណាមក បើគ្រួសារខ្ញុំមានតែខ្ញុំម្នាក់គត់ ដែលកើតជំងឺឃ្លង់?

My wife does not have free time. From early morning until evening, she works as a tailor sewing clothes for villagers in order to make some earning. Her earning is supporting our family for food and for our living. Presently, my family life is going very well. Sometimes I wonder that it seems a mystery that I had leprosy even though there is nobody in my family who had leprosy.



កូនខ្ញុំបានចូលរៀន ហើយការសិក្សារបស់ពួកគាត់ ដំណើរការបានល្អណាស់ ។ គ្មាននរណាម្នាក់ក្នុងភូមិរើសអើងខ្ញុំទេ ផ្ទុយទៅវិញ គេកោតសរសើរខ្ញុំ ព្រោះខ្ញុំចេះតស៊ូស្វិតស្វាញក្នុងការរកជីវិត ខ្ញុំរស់នៅយ៉ាងរីករាយជាមួយគ្រួសាររបស់ខ្ញុំ ។

***My children go to school and study well. No one in my village discriminates against me. On the contrary, they admire me because I am working very hard for my living. I live happily with my family.***

តាំងពីច្រើនជំនាន់មកហើយ ខ្ញុំពុំដែលឮចាស់ៗ ឬអ្នកជិតខាងណាម្នាក់និយាយពីពូជនាងខ្ញុំថា ជាត្រកូលអ្នកកើតជំងឺឃ្លង់សោះ ចុះហេតុអ្វីក៏ព្រេងវាសនាតម្រូវឱ្យរូបខ្ញុំកើតរោគឃ្លង់បែបនេះ? ពេលនាងខ្ញុំធំដឹងក្តីពេលណា ម្តាយឪពុកចិញ្ចឹមគាត់និយាយថា ខ្ញុំជាអ្នកស្រុកកំពង់ឈើទាល ឃុំសំបូរ ស្រុកកំពង់ស្វាយ ខេត្ត កំពង់ធំនេះតែម្តង។ ខ្ញុំជាក្មេងកំព្រាម្នាក់ដែលសែនអភ័ព្វមហាអភ័ព្វ កើតមកបានប្រហែលជាប្រាំឆ្នាំ ឪពុកម្តាយក៏មានជំងឺគ្រុនចាញ់ ស្លាប់ទាំងប្តីប្រពន្ធទាំងបិទភ្នែក មិនជិត។ ពេលដែលអ្នកមានគុណទាំងពីរបានលាចាកលោកនេះទៅ ខ្ញុំបានពូមីងដែល ជាអ្នករស់នៅជិតខាង បានចិញ្ចឹមបីបាច់ថែរក្សាដូចជាកូនបង្កើតគាត់យ៉ាងនោះដែរ។ យោងទៅតាមជីវភាពខ្វះខាតរបស់គាត់ទាំងពីរ ទើបខ្ញុំពុំបានស្គាល់សាលារៀនយ៉ាងម៉េចទេ ព្រោះមួយថ្ងៃៗដើរបេះបន្លែព្រៃយកទៅលក់ឯផ្សារ គ្រាន់ទិញអង្ករបរិភោគ។ លុះដល់នាងខ្ញុំធំពេញវ័យ គាត់ក៏ឱ្យនាងខ្ញុំរៀបការជាមួយក្មួយប្រុសគាត់ម្នាក់ ដែលមានអាយុប្អូនខ្ញុំរហូតដល់ទៅបីឆ្នាំ។ ពេលរៀបការបានមួយឆ្នាំ គឺប្រហែលជាឆ្នាំ ១៩៩៨ នាងខ្ញុំក៏សម្រាលបានកូនប្រុសមួយ ដែលមានរូបសម្ផស្សគួរជាទីស្រឡាញ់ពេញចិត្ត។

Many generations have passed, but I had never heard the elderly people or my neighbors telling me that my ancestor had leprosy. Why did destiny made me have leprosy? When I grew up, my adopted parents told me that I was living in Kampong Cheouteal district, Kampong Thom province. I was an unlucky child because when I was about five years old, my parents passed away due to malaria. As I was orphaned, I lived with my uncle and aunt who were my neighbors. They looked after me like their own child but they were poor so they could not send me to school. I went to the forest to cut vegetables and to tend rice fields for supporting family. When I grew up, I married to their nephew who was three years younger than I was. After I had married for a year in 1998, I had a cute baby.

លុះកូននាងខ្ញុំអាយុបានប្រាំមួយខែ ស្រាប់តែស្លាកស្នាមពណ៌សមួយ លេចធ្លោនៅលើដើមទ្រូងខាងឆ្វេង ខ្ញុំសួរឆ្មបដែលបង្កើតកូនឱ្យខ្ញុំ ។ គាត់ថាប្រហែលមកពីខ្ញុំខ្វះវីតាមីនទេទើបបណ្តាលឱ្យចេញស្នាមសបែបនេះ ។ ទោះបីមានស្លាកស្នាមខុសធម្មតាក៏ដោយក៏នាងខ្ញុំមិនខ្វល់សោះឡើយ គឺពីរនាក់ប្តីប្រពន្ធនៅតែប្រឹងរករបរចិញ្ចឹមជីវិត ជាប្រក្រតីដដែល ។ នៅឆ្នាំ២០០០ នាងខ្ញុំក៏សម្រាលបានកូនស្រីម្នាក់ទៀត រូបរាងស្អាតបាតល្អណាស់ ។ ខណៈដែលកូននាងខ្ញុំមានអាយុប្រាំបីខែ ស្រាប់តែមានអព្ភូតហេតុមួយដ៏អាក្រក់កើតលើខ្ញុំ ។ រាងកាយខ្ញុំមានស្លាកស្នាមយ៉ាងច្រើន ហើយជើងទាំងសងខាងមានភាពស្ពឹកកម្រើកលែងរួចតែម្តង ។ ខណៈនោះចាស់ទុំជិតខាង យល់ថាខ្ញុំទាស់សរសៃខ្ចី ប្តីខ្ញុំក៏ខិតខំរកថ្នាំបូរាណមកព្យាបាល តែវាគ្មានប្រសិទ្ធភាពទាល់តែសោះ ។ គាប់ជួនពេលនោះ ស្រាប់តែផលបុណ្យខ្ញុំល្អ ស្រាប់តែមានរថយន្តពណ៌សមួយគ្រឿងដែលបើកបរដោយលោក *ពៅ មុនី* បានដឹកនាំខាងកម្មវិធីប្រយុទ្ធនឹងជំងឺហង់សិន ខេត្តកំពង់ធំ និងលោកវេជ្ជបណ្ឌិត *ធារ៉ាត់*តំណាងកម្មវិធីជាតិចុះមកដល់ផ្ទះនាងខ្ញុំតែម្តង ។

When my child was 6 months of age, one white skin patch appeared on my left chest. I asked the midwife who delivered my baby about the patch. She told me that I might have vitamin deficiency and that was why I had that skin lesion. It was a strange skin sign but I did not care much about it. My husband and I were worried only about sustaining our living. In 2000, I had another child, she was also very cute. When my baby was 8 months old, a mystery of my life happened to me. My body was covered with full of skin lesions and my feet could not move. The elderly who lived near my house said that I was tired because of the delivery of the baby. My husband tried to find Khmer traditional medicine, but it did not make me better.
It was my luck when a white car driven by Mr. *Pov Mony*, a provincial leprosy supervisor and Dr. *Therath,* national leprosy supervisor came to my house.

លោកវេជ្ជបណ្ឌិតពិនិត្យតែមួយភ្លែត គាត់ក៏បញ្ជាឱ្យប្ដីខ្ញុំ និងខ្ញុំរៀបចំឥវ៉ាន់ សម្លៀកបំពាក់ ដើម្បីទៅព្យាបាលនៅមន្ទីរពេទ្យគៀនឃ្លាំង ឯជ្រោយចង្វារ រាជធានីភ្នំពេញ។ នាងខ្ញុំនៅសម្រាកព្យាបាលដោយលេបថ្នាំច្រើនមុខMDT និងអប់រំចលនា និងរួមផ្សំបន្ថែមដោយថ្នាំប្រតិកម្ម អស់រយៈពេលប្រហែលបីខែ ទើបគ្រូពេទ្យសម្រេចចិត្តធ្វើការវះកាត់ជើងនាងខ្ញុំអាចកម្រើកនិងដើរបានប្រហែលជាក្នុងឆ្នាំ២០០៣។ ក្រោយពីបានបញ្ចប់ព្យាបាលបានជាស្រួលបួលហើយ ខ្ញុំនិងប្ដីព្រមទាំងកូនតូចដែលនៅបៅដោះក៏វិលមកលំនៅដ្ឋានវិញ ចាប់ប្រកបមុខរបរចិញ្ចឹមជីវិតជាធម្មតា។ លុះមកដល់ឆ្នាំ២០០៥ ប្រហែលជាថ្ងៃចូលឆ្នាំប្រពៃណីជាតិ ខ្ញុំក៏សម្រាលបានកូនប្រុសម្នាក់ទៀត។ នៅដើមឆ្នាំ២០០៧ ស្រាប់តែប្ដីនាងខ្ញុំឈ្មោះ *ឡេង គីមលន* បានលេចរោគសញ្ញាយ៉ាងច្បាស់នៅខ្នងផ្នែកខាងស្ដាំ ដែលសណ្ឋានដូចផែនទី ហើយជុំវិញស្នាមនោះមានស្នាមអមតូចៗពីរបីថែមទៀត។ ខ្ញុំឃើញភ្លាម ក៏ប្រញាប់តឿនគាត់ឱ្យទៅពិនិត្យនៅខេត្តកំពង់ធំ។ លុះបានពិនិត្យចប់សព្វគ្រប់ហើយលោកគ្រូពេទ្យបានឱ្យប្ដីនាងខ្ញុំលេបថ្នាំច្រើនមុខMDT រយៈពេលប្រាំមួយខែ។

Doctor examined me for a while and he suggested me to go to Kien Khleang Leprosy Rehabilitation center in Chruy Changva Village, Phnom Penh. I was treated with MDT and physical therapy including reaction medicine. In 2003, I had reconstructive surgery on my feet. I finished my treatment and I came back home with my husband and started my business again as before. In 2005, I had another son. In 2007, my husband, Mr. *Leng Kim Lorn*, had skin sign which looked like a map. He developed small patches nearby the skin patch as well. I forced him to consult at Kampong Thom town. After consulting with the health professional staff, my husband took MDT for 6 months.

ក្រោយមកទៀត មន្ត្រីនៃកម្មវិធីជាតិតែងតែមកតាមដានជំងឺខ្ញុំ និងប្តីខ្ញុំ ជាពិសេស កូនៗខ្ញុំមិនសូវលោះពេលទេ ដោយគាត់ផ្តែផ្តាំដល់ប្តីខ្ញុំ និងខ្ញុំឱ្យឧស្សាហ៍ពិនិត្យស្បែក លើខ្លួនកូន បើមានសញ្ញាដូចជា ស្រែងឬភ្លឺឱ្យប្រញាប់ប្រាប់គាត់។ តាំងពីថ្ងៃនោះមក ខ្ញុំរស់នៅប្រកបដោយ សុភមង្គលល្អណាស់ គឺប្តីខ្ញុំមានជំនាញដើរទិញម៉ូតូចាស់ៗ យកមកជួសជុលលក់។ រីឯនាងខ្ញុំវិញ នៅផ្ទះចិញ្ចឹម ជ្រូក មាន់ ទា និងថែទាំកូនៗបាន ល្អប្រសើរណាស់។ សព្វថ្ងៃ កូនទាំងខ្ញុំបានចូលសាលារៀនម្នាក់ហើយ គេរៀនឆ្លាត ណាស់ ចំពោះអ្នកភូមិផងរបងជាមួយ គ្មាននរណារើសអើងនឹងគ្រួសារខ្ញុំទេ ផ្ទុយ ទៅវិញ គេនាំគ្នាសរសើរ គ្រប់ៗគ្នាថា ចេះតស៊ូស្វិតស្វាញក្នុងឆាកជីវិតទៀតផង។

Then the National Leprosy Program staffs ever came to my house to follow up treatment on me and my husband. They also recommended me to check my children for any strange skin signs which was like a ring worm and told me to make sure we come to check as soon as if we find any possible signs. Since then, I have lived happily with my family. My husband buys old motorbikes, repairs and sells them back to the villagers. Besides this I do chicken and pig raisings and look after my children. Nowadays all my children go to school. They are cleaver and study well. No one in my village discriminates against me. On the contrary, they admire me because I am working very hard for my living.

**កម្មវិធីជាតិកំចាត់រោគហង់សិន**

នៃមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និង

ហង់សិន នៃក្រសួងសុខាភិបាល

*ទីស្នាក់ការ:* សង្កាត់ព្រែកលាប ខណ្ឌឫស្សីកែវ

រាជធានីភ្នំពេញ

ទូរស័ព្ទ: 023-432057

Tel&Fax: +855-23-432057
E-mail: NLEP.CENAT@online.com.kh

សូមថ្លែងអំណរគុណចំពោះ អស់លោកអ្នក ដែលបានចូលរួមទាំងកម្លាំងកាយ និងសម្ភារៈ ព្រមទាំងផ្តល់នូវរូបថត ដើម្បីឱ្យការចងក្រងបោះពុម្ពផ្សាយទទួលបានជោគជ័យ ។



FINE
